# ឥតិបិសោរតនមាលាបាលិ~ប្រែ

# នមក្ការបាលិ~ប្រែ


*ប្រែ-រៀបរៀងដោយ*

**ធម្មានន្ទ អ៊ាន់ ចាន់សារ៉េន**

*អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*



*ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*ព.ស.២៥៥៤*

---

*ឆ្នាំ ២០១១*

ឈ្មោះសៀវភៅ ឥតិបិសោរតនមាលាបាលី-ប្រែ
នមក្ការបាលី-ប្រែ
ប្រែ-រៀបរៀងដោយ ធម្មានន្ទ ហ៊ន់ ចាន់សារ៉ែន
ឧទ្ទិសបំពោះ បណ្ឌិត កុល ផេង
កាលបរិច្ឆេទ ១៥ កើត ខែ ពិសាខ ព.ស.២៥៥៤
ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១
ការផ្សាយ របស់ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យ
បញ្ញាសាស្ត្រកម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង ដោយពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យ
បញ្ញាសាស្ត្រកម្ពុជា

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# ឧទ្ទិសកថា

ក្នុងការប្រែ-រៀបរៀងនិងចាត់ការបោះពុម្ពសៀវភៅឥតិបិសោរតន-មាលានេះ ដែលសរសើរដល់គុណព្រះពុទ្ធ ៥៦ គុណព្រះធម៌ ៣៨ និងគុណនៃព្រះសង្ឃ ១៤ និងនមក្ការបាលី-ប្រែ ដែលមានពណ៌នាគុណព្រះពុទ្ធរកប្រមាណមិនបាន របស់សមាជិកសមាជិកានៃពុទ្ធិកបណ្ឌិតសភានៃសាកល-វិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដើម្បីបានចំណែកបុណ្យកុសលនេះ ជូនចំពោះ **បណ្ឌិត ករុល ផេង** បិតាស្ថាបនិកនៃពុទ្ធិកបណ្ឌិតសភានៃសាកល-វិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយសូមបានកុសលកម្មនេះ ជាឧបត្ថម្ភកម្មដល់ជនកកម្ម ដែលបានដើរតួបដិសន្ធិ និងឲ្យផលក្នុងបវត្តិកាល សូមបានជាបច្ច័យនៃការមិនមានរោគ សុខភាពល្អ អាយុវែង វណ្ណៈពណ៌សម្បុរផូរផង់ សុខក្នុងផ្លូវចិត្ត និងផ្លូវកាយ មានកម្លាំងពលំខ្លាំងក្លា ប្រាជ្ញាវាងវៃ ។

ដោយតេជានុភាពនៃធម្មទាននេះ សូម **លោកបណ្ឌិត** ត្រេកអរប្រកបដោយបីតិប្រាមោជ្ជអនុមោទនាទទួលយកបុណ្យកុសលនេះ ហើយបានជាបច្ច័យនៃការរួចផុតចាកទុក្ខទាំងពួង ។

សូម **លោកបណ្ឌិត** ទទួលនូវសេចក្តីគោរពស្រឡាញ់ដ៏ស្មោះនិងប្រកបដោយកតញ្ញូតាធម៌ពីយើងខ្ញុំ ។

ម្យ៉ាងទៀត សូមប្រគេនបុណ្យកុសលនេះ ចំពោះព្រះគុណម្ចាស់គ្រប់ព្រះអង្គ និងសាធុសប្បុរសទាំងអស់ ដែលបានចូលរួមផ្សាយព្រះធម៌និងបោះពុម្ពសៀវភៅជាបន្តបន្ទាប់ ក្នុងពុទ្ធិកបណ្ឌិតសភានេះ ដោយតេជះ

*គុណានុភាពនៃធម្មទាននេះ សូមព្រះគុណម្ចាស់ សាធុសប្បុរសបានជួប ប្រសព្វនូវសេចក្ដីសុខគ្រប់ប្រការ និងធម៌ប្រសើរ ៤ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជាបច្ច័យនៃបញ្ញាសម្មាទិដ្ឋិ រួចផុតចាកទុក្ខ កុំបីឃ្លៀងឃ្លាតឡើយ ។*

*ពុទ្ធិកបណ្ឌិតសភា, ១៥ កើតពេញបូណ៌មី ខែ ពិសាខ ព.ស.២៥៥៤*

*ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១*

**សមាជិក សមាជិកាពុទ្ធិកបណ្ឌិតសភា**

# អនុមោទនកថា

ខ្ញុំសូមកោតសរសើរដោយសុទ្ធចិត្តចំពោះសមាជិក សមាជិកាពុទ្ធិក-បណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាទាំងអស់ ដែលបានព្យាយាមប្រែ-រៀបរៀងសៀវភៅធម៌ **ឥតិបិសោរតនមាលាបាលី~ប្រែ** និង **នមក្ការបាលី~ប្រែ** ដើម្បីបានបុណ្យកុសលជូនចំពោះខ្ញុំ សម្រាប់តាំងនៅដោយអាយុវឌ្ឍនៈនិងជៀសផុតពីឧបសគ្គអន្តរាយផ្សេងៗ ដោយគុណានុភាពនិងតេជៈនៃព្រះពុទ្ធគុណ ព្រះធម្មគុណ និង ព្រះសង្ឃគុណ ។ ជាពិសេស **លោកគ្រូ ធម្មានន្ទ** ផ្ទាល់ ដែលជាអ្នកខិតខំ ប្រែ-រៀបរៀងចងក្រងឲ្យបានសម្រេចជារូបរាងសៀវភៅនេះឡើង ។

ខ្ញុំសូមអនុមោទនាប្រកបដោយបីតិប្រាមោទ្យសោមនស្សរីករាយទទួលយកនូវបុណ្យកុសលនេះ ជាបុញ្ញនិធិដ៏ប្រសើរខ្ពង់ខ្ពស់បំផុត ។

ខ្ញុំក៏សូមជូនចំណែកបុណ្យកុសលទាំងអស់ ដែលខ្លួនខ្ញុំបានបំពេញហើយ ទោះជាអាមិសទានក្តី ធម្មទានក្តី អភយទានក្តី ដល់សមាជិក សមាជិកាពុទ្ធិកបណ្ឌិតសភាទាំងអស់ សូមត្រេកអរអនុមោទនាទទួលយក ហើយបានជាបច្ច័យនៃសេចក្តីសុខ ក្នុងជាតិនេះ និងជាតិខាងមុខ ហើយបានរួចផុតចាកសង្សារវដ្ត កុំបីឃ្លាងឃ្លៀតឡើយ ។

ខ្ញុំសូមផ្សាយមេត្តាធម៌ដល់សព្វសត្វទាំងឡាយ :

សព្វេ សត្តា អវេរិនោ ហោន្តុ

សូមសត្វលោកទាំងឡាយ កុំមានពៀរនឹងគ្នា

សព្វេ សត្តា ខេមិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយ បានដល់នូវសេចក្តីក្សេម*

សព្វេ សត្តា សុខិនោ ហោន្តុ

*សូមសត្វលោកទាំងឡាយបានប្រកបដោយសេចក្តីសុខជានិច្ចនិរន្តរ៍!*

*ថ្ងៃ ១៥ កើត ខែ ពិសាខ ព.ស.២៥៥៤*

*ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា គ.ស.២០១១*

**កុល ផេង**

*ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

# បុព្វកថា

**ឥតិបិសោរតនមាលា** នេះ មានគាថាសរុប ១០៨ គាថា ដែលបាន ពណ៌នានូវគុណព្រះពុទ្ធ ៥៦ គាថា គុណព្រះធម៌ ៣៨ គាថា និងគុណព្រះសង្ឃ ១៤ គាថា ។ របៀបនៃគាថា អ្នករចនាបានដកស្រង់ក្នុងបទធម៌ដែលពណ៌នាគុណព្រះពុទ្ធ គឺឥតិបិសោ ភគវា...ដោយបានលើកយកពាក្យមួយព្យាង្គម្តងៗ ទៅពង្រីកជាគាថាមួយ, ក្នុងគុណព្រះធម៌ក៏ដូចគ្នា ដោយបានដកស្រង់ចេញពីគុណព្រះធម៌ គឺស្វាក្ខាតោ ភគវតា ធម្មោ...ចំណែកឯគុណព្រះសង្ឃបានដកស្រង់ចេញពី សុប្បដិបន្នោ... តែមិនពណ៌នាគ្រប់ព្យាង្គទាំងអស់នោះទេ ពណ៌នាត្រឹម ១៤ ព្យាង្គប៉ុណ្ណោះ ។

ឥតិបិសោរតនមាលានេះ ខ្ញុំមានសេចក្តីសន្និដ្ឋានថា បានរចនាដោយព្រះមហាថេរៈអង្គណាមួយ ដែលគង់នៅតំបន់ចៀងម៉ៃ ហើយនិពន្ធក្នុងសម័យជាមួយនឹងគាថាជិនបញ្ជរ ឧប្បាតសន្តិ ពុទ្ធនវមនមក្ការៈ ឬពុទ្ធជយមង្គលគាថា (ធម៌ពាហុំ) មិនខាន ។ គាថាទាំងនេះ ត្រូវនាំបន្តគ្នាតាមគម្ពីរស្លឹករឹតតៗគ្នា ។ ក្នុងសម័យមុន ខ្មែរយើងនិយមយកគាថាទាំងនេះ ទៅធ្វើជាមន្តអាគម ចារយន្ត ចារកថា សូធ្យការពារអំពើផ្សេងៗ ។ ខ្ញុំធ្លាប់ឃើញមាននៅក្នុងសៀវភៅខ្លះៗ បានដកយកមួយគាថា ឬពីរគាថា ហើយបញ្ជាក់ថា មន្តអាគមការពានេះ ការពារនោះ ដូចខ្មែរយើងនិយមហៅមន្តមួយមានឈ្មោះ **មន្តមណីចិន្តា** ថាជាមន្តស័ក្តិសិទ្ធ ឲ្យគេស្រឡាញ់ ឲ្យគេអាណិតៗ តាមពិតមន្តនេះ ដកចេញពី*ឥតិបិសោរតនមាលា* ត្រង់គាថាទីបី :

បិយោ ទេវមនុស្សានំ    បិយោ ព្រហ្មានមុត្តមោ
បិយោ នាគសុបណ្ណានំ  បិណិន្ទ្រិយំ នមាមិហំ ។

*កាលដកស្រង់គាថានេះ ហើយយកទៅលាយជាមួយនឹងការផ្សាយមេត្តាធម៌ ដល់មនុស្សទេវតាជាដើម ក៏សម្រេចជារូបមន្តមណីចិន្តាដូច្នេះ :*

**មណីចិន្តា សហស្សកោដិទេវានំ មនុស្សទេវានំ សមណចិត្តំ បុរិសចិត្តំ អាគច្ឆាហិ បរិទេវន្តិ បិយំ មម សព្វជនា ពហុជនា មហាមណីចិន្តា ឯហិ ពុទ្ធំ បិយោ ទេវមនុស្សានំ មហាមណីចិន្តា ឯហិ ធម្មំ បិយោ ព្រហ្មានមុត្តមោ មហាមណីចិន្តា ឯហិ សង្ឃំ បិយោ នាគសុបណ្ណានំ បិណិន្ទ្រិយំ នមាមិហំ ពុទ្ធោ សោ ភគវា ធម្មោ សោ ភគវា សង្ឃោ សោ ភគវា ឥន្ទសេនេហា ព្រហ្មសេនេហា ឥត្ថីសេនេហា រាជាទេវី មណីរត្នំ ចិត្តំ បិយំ មម ។**

*យ៉ាងណាក៏ដោយ ទោះបីគាថាឥតិបិសោរតនមាលាទាំងនេះ កែច្នៃទៅជាយ៉ាងណា ក៏នៅតែជាពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ ។*

*បទគាថាទាំងនេះ ជាបទគាថាដែលគួរដល់កិរិយានមស្ការថ្វាយបង្គំ ចម្រើននូវពុទ្ធានុស្សតិ រលឹកដល់គុណនៃព្រះពុទ្ធ, ធម្មានុស្សតិ រលឹកដល់គុណនៃព្រះធម៌, សង្ឃានុស្សតិ រលឹកដល់គុណនៃព្រះសង្ឃ នាំឲ្យយើងបានសម្រេចនូវបុណ្យកុសលរាប់ប្រមាណមិនបាន ដូចព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា :*

តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ
ន សក្កា បុញ្ញំ សង្ខាតុំ យមេត្តមបិ កេនចិ ។

*សូម្បីបុគ្គលណាមួយក្នុងលោកនេះ មិនអាចនឹងរាប់ផល
បុណ្យ របស់អ្នកបូជាព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវក
ដែលស្ងប់រំងាប់ មិនមានភ័យដោយប្រការទាំងពួង ។*

*ម្យ៉ាងទៀត មិនមែនសម្រេចតែបុណ្យកុសលក្នុងអនាគតកាល
នោះទេ តែអាចជួយការពារអន្តរាយច្រើនយ៉ាង មិនឲ្យកើតមានដោយ
អំណាចនៃឧបត្ថម្ភកម្ម ចូលទៅជួយឧបត្ថម្ភដល់ជនកកម្ម ដូចព្រះញាណធជ
មហាថេរលើកសម្ដែងក្នុងគម្ពីរបរមត្ថទីបនី សង្គហមហាដីកាថា ៖*

*ចេតនាក្នុងការនមស្ការថ្វាយបង្គំព្រះរតនត្រ័យ ជាឧបត្ថម្ភកម្មចូល
ទៅជួយទំនុកបម្រុងដល់ជនកកម្ម ដែលជាកុសលបង្កឲ្យកើតខន្ធជាវិបាក
និងកដត្តារូប (កម្មជរូប) ក្នុងបដិសន្ធិកាល និងបវត្តិកាល ។ ការឧបត្ថម្ភ
ដល់ខន្ធ ដែលកើតអំពីកម្ម គឺការធ្វើឲ្យពួកខន្ធមានដំណើរការទៅយូរជាង
ដើម ដោយកម្ចាត់អន្តរាយនៃជីវិតរបស់ខ្សែខន្ធ ដែលកើតអំពីអកុសលកម្ម
ដោយការនាំគ្រឿងឧបត្ថម្ភជីវិតចូលមកដោយល្អ ដូចព្រះពុទ្ធវចនៈថា*

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ។

*ធម៌ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ រមែងចម្រើន
ដល់អ្នកថ្វាយបង្គំព្រះរតនត្រ័យ និងអ្នកគោរពកោតក្រែង
ដល់អ្នកចម្រើនដោយវុឌ្ឍិគុណ អស់កាលជានិច្ច ។*

ជំនាន់អដ្ឋកថាចារ្យ តែងតែនមស្ការព្រះរតនត្រ័យជាដំបូង ទើបលោកផ្ដើមរចនាគម្ពីរ ។ ក្នុងទីបញ្ចប់បទនមស្ការរបស់លោក តែងតែអាងអានុភាពនៃការថ្វាយបង្គំ សូមឲ្យកម្ចាត់នូវអន្តរាយទាំងឡាយ មានអន្តរាយនៃជីវិតជាដើម ដូចក្នុងសមន្តបាសាទិកា ធ្វើបទនមស្ការចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃហើយ មានពាក្យខាងចុងថា ៖

ឥច្ចេវមច្ចន្តនមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ។

ខ្ញុំបាននមស្ការនូវព្រះរតនត្រ័យ
ដែលគួរដល់ការនមស្ការដូចពោល
មកនេះ បាននូវអានិសង្សគឺបុណ្យ
ដ៏ធំទូលាយឯណា សូមអន្តរាយ
ចូរវិនាសបាត់ទៅ ដោយអានុភាព
នៃបុណ្យនោះ ។

នៅក្នុងគម្ពីរអដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណី អភិធម្ម ព្រះពុទ្ធ-ឃោសាចារ្យ ក្រោយពីនមស្ការបានពោលពាក្យបញ្ចប់ថា ៖

និបច្ចការស្សេតស្ស កតស្ស រតនត្តយេ
អានុភាវេន សោសេត្វា អន្តរាយេ អសេសតោ។

ខ្ញុំ (អដ្ឋកថាចារ្យ) បានកម្ចាត់ឧបសគ្គទាំងពួង ដោយ
អានុភាពនៃការគោរពថ្វាយបង្គំ ដែលធ្វើហើយ ក្នុង
ព្រះរតនត្រ័យ ។

សូម្បីដីកាចារ្យ ក៏បានអធិប្បាយអានិសង្សទុកក្នុងគម្ពីរដីកាផ្សេងៗ ជាច្រើន នូវអានិសង្សថ្វាយបង្គំព្រះរតនត្រ័យ ។

សួរថា ការថ្វាយបង្គំព្រះរតនត្រ័យ អាចកម្ចាត់ឧបសគ្គយ៉ាងណា?

តបថា ការថ្វាយបង្គំព្រះរតនត្រ័យ ជាក្រសែបុណ្យដ៏ធំ ញ៉ាំងកិរិយានមស្ការថ្វាយបង្គំឲ្យសម្រេច ប្រព្រឹត្តទៅគ្រប់ៗ ជវនចិត្ត ៧ ខណៈ រហូតច្រើនសែនកោដិជង ។

ក្រសែបុណ្យនោះ ជាបុណ្យធំទូលាយ មានអានុភាពច្រើន មានផលច្រើន ព្រោះចម្រើនក្នុងស្រែបុណ្យដ៏ខ្ពង់ខ្ពស់ មានព្រះពុទ្ធជាដើម និងបានចម្រើនដោយគុណ មាន ឆន្ទៈ សទ្ធា និងបញ្ញា ។ បុណ្យដ៏មហាសាលនោះទ្រទ្រង់ក្នុងការដល់ព្រមដោយសេចក្ដីព្យាយាម កម្ចាត់ហេតុវិបត្តិខាងក្រៅជាហេតុឲ្យបានទទួលសម្បត្តិ ធ្វើសេចក្ដីចម្រើនដល់ធាតុទាំង ៤ ដែលទ្រទ្រង់ក្នុងរាងកាយដែលកើតពីឧតុ ចិត្ត និងអាហារដ៏ប្រណីត ឧបត្ថម្ភដល់ជនកកម្ម ដែលបានទទួលឱកាសតាំងពីបដិសន្ធិកាល និងបានឱកាសជួយឧបត្ថម្ភដល់កុសលដទៃ ដែលមិនមានឱកាសឲ្យផល ។

លំដាប់នោះ ក្រសែរូបធម៌ នាមធម៌ ដែលកើតអំពីបុណ្យទាំង ២ ទទួលបានកម្លាំងឧបត្ថម្ភនិងបានឱកាសបញ្ជូនផលឲ្យ មានកម្លាំងបន្តដំណើរជីវិតទៅ ធ្វើឲ្យឧបសគ្គគឺរោគជាដើម ដែលឲ្យផលមិនល្អ មិនមានឱកាសឲ្យផល មានត្រឹមតែឱកាសផលល្អតែម្យ៉ាង រហូតដល់ទីបំផុតអាយុកប្ប ។

## **ការថ្វាយបង្គំ ៣ យ៉ាង**

*(គម្ពីរបរមត្ថទីបនី សង្គហមហាដីកា និងនមក្ការដីកា)*

*ការថ្វាយបង្គំមាន ៣ យ៉ាង ដោយចំណែកក្នុងការថ្វាយបង្គំផ្លូវកាយជាដើម សមដូចព្រះពុទ្ធវចនៈថា ៖*

តិស្សោ ឥមា ភិក្ខវេ វន្ទនា ។ កតមា តិស្សោ ? កាយេន វន្ទតិ, វាចាយ វន្ទតិ, មនសា វន្ទតិ ។

*ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំ មាន ៣ យ៉ាង ។ ៣ យ៉ាងនោះតើដូចម្ដេច ? ការថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១ ។*

*បុគ្គលណាមានចិត្តដ៏ប្រសើរឲ្យតាំងនៅចំពោះមុខ ហើយញុំាងអវយវៈទាំង ៥ គឺជើង ២ ដៃ ២ ក្បាល ១ ឲ្យតាំងនៅត្រង់ផ្ទៃ ក្រាបចុះចំពោះមុខអ្នកដែលគួរដល់ការថ្វាយបង្គំ ហៅថា **ថ្វាយបង្គំដោយកាយ** ។*

*អ្នកពោលស្វាធ្យាយសម្ដែងគុណសម្បត្តិដោយវាចា ហៅថា **ថ្វាយបង្គំដោយវាចា** ដូចពោលថា* នមោ ពុទ្ធស្ស, នមត្ថុ ពុទ្ធស្ស, នមោ វិមុត្តិយា, នមោ វិមុត្តានំ, វិបស្សិស្ស នមត្ថុ *ជាដើម ចាត់ជាការថ្វាយបង្គំដោយវាចា ។*

*ចំណែកការរលឹកដល់គុណសម្បត្តិស្មើ ដោយបណ្ដោយតាមពាក្យសម្ដែងគុណសម្បត្តិ ហៅថា **ថ្វាយបង្គំដោយចិត្ត** ។*

## អានិសង្សចាំគាថាពណ៌នាគុណព្រះរតនត្រ័យ

ឥត្ថំ អសង្ខ្យេយ នាថ- គុណោ លក្ខណាទីបិតេ
គាថាសុ សូចកាស្វេក- គាថម្បិ សរតេ ពុធោ ។

*បណ្ឌិតណា កាលបានឮគេប្រកាសគុណលក្ខណៈ របស់ព្រះលោកនាថ ដែលប្រមាណមិនបាន ដោយប្រការដូច្នេះហើយ ទ្រទ្រង់ចាំគាថា ១ គាថា ក្នុងបណ្ដាគាថាទាំងឡាយបាន ។*

ចតុរាបាយមុត្តោ សោ សាធកត្ថទ្វយស្ស ច
ហត្វូបទ្ទវជាលោ ច លាភី ហិតសុខស្ស ច ។

*បណ្ឌិតនោះ នឹងរួចផុតចាកអបាយភូមិទាំង ៤ នឹងជាអ្នកញុំាងប្រយោជន៍ទាំងពីរឲ្យសម្រេច នឹងជាអ្នកកម្ចាត់សំណាញ់ គឺឧបទ្រពបាន នឹងបានទទួលប្រយោជន៍ជាសុខ ។*

អធិតោ នរទេវានំ ចតុទីបិស្សរោបិ វា
ភវេយ្យ អន្តិមេ ទេហោ តមញ្ញំ សេតជត្តកំ ។
ភាវនាយានមារុយ្ហ សមមេស្សតិ សុព្វតោ
ឥមស្មឹ អត្ថភាវេបិ អរោគោ ទីឃជីវិកោ ។

នឹងជាធំក្នុងទេវតានិងមនុស្ស នឹងកើតជាស្តេចចក្រពត្តិ ជាធំក្នុងទ្វីបទាំង ៤ ក្នុងអត្តភាពចុងបំផុត នឹងជាអ្នកមានសេចក្តីប្រព្រឹត្តល្អ ឡើងកាន់យាន គឺភាវនា ដែលទ្រទ្រង់ទុកនូវស្វេតច្ឆត្រ គឺអរហត្តផលនោះ ទៅដល់ព្រះនិព្វាន សូម្បីក្នុងអត្តភាពនេះ ក៏នឹងជាមនុស្សមានអាយុវែង មិនមានរោគ ។

បូជិតោ សព្វលោកេហិ   ភាវនាភិរតីមនោ

ជនប្បិយោ មនាបោ ច   កា កថាទិលធារណោ។

ជាអ្នកមានចិត្តត្រេកអរក្នុងភាវនា ជាអ្នកដែលមនុស្សលោកទាំងពួង គោរពបូជាហើយ ជាទីស្រឡាញ់ ជាទីពេញចិត្តនៃមហាជន នឹងចាំបាច់ពោលទៅថ្វី ក្នុងការការទ្រទ្រង់ចាំគាថាបានទាំងអស់ ។

ថ្ងៃ ១៥ កើតពេញបូណ៌មី ខែ ពិសាខ ព.ស.២៥៥៤

ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

**ធម្មានន្ទ ទ៊ាន់ ចាន់សារ៉ែន**

អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

# ឥតិបិសោរតនមាលា

## ព្រះពុទ្ធគុណ ៥៦

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ឥតិបិ សោ ភគវា អរហំ *ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺ កិលេសព្រមទាំងវាសនាគឺ កាយប្បយោគនិងវចីបយោគ* សម្មាសម្ពុទ្ធោ *ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ* វិជ្ជាចរណសម្បន្នោ *ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥* សុគតោ *ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថានគឺអមតមហានិព្វាន* លោកវិទូ *ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក* អនុត្តរោ *ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន* បុរិសទម្មសារថិ *ទ្រង់*

ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន សត្ថា ទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គ ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

៩. ឥដ្ឋោ សព្វញ្ញុតញ្ញាណំ ឥច្ឆន្តោ អាសវក្ខយំ
ឥដ្ឋំ ធម្មំ អនុប្បត្តោ ឥទ្ធិមន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រាថ្នាសព្វញ្ញុតញ្ញាណ
គ្មានធុញថប់ត្រឡប់ថយក្រោយ ពុំមានព្វោយទាល់ក្ស័យ
អាសវៈ ទ្រង់ទម្លុះនូវធម៌ដែលព្រះអង្គប្រាថ្នាហើយ
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមាន
សេចក្តីប្រាថ្នាសម្រេចហើយ ។

តិ. តិណ្ណោ យោ វដ្តទុក្ខម្ហា តិណ្ណំ លោកានមុត្តមោ
តិស្សោ ភូមី អតិក្កន្តោ តិណ្ណោឱឃំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ឆ្លងចាកទុក្ខក្នុងវដ្តៈទាំង ៣
ភូមិទាំង ៣ ហើយព្រះអង្គប្រសើរឧត្តម ខ្ញុំសូមនមស្ការ

*នូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលបានឆ្លងឱឃៈហើយ ។*

បិ. បិយោ ទេវមនុស្សានំ បិយោ ព្រហ្មានមុត្តមោ
បិយោ នាគសុបណ្ណានំ បិណិន្ទ្រិយំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ជាទីស្រឡាញ់នៃទេវតានិង មនុស្សទាំងឡាយ ជាទីស្រឡាញ់ដ៏ខ្ពង់ខ្ពស់នៃព្រហ្ម ទាំងឡាយ ជាទីស្រឡាញ់នៃនាគនិងគ្រុឌទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមាន ឥន្ទ្រិយស្មើត្រឹម ។*

សោ. សោកា វិរត្តចិត្តោ យោ សោកមានោ សទេវកេ
សោកបត្តេ បមោទេន្តោ សោភវណ្ណំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ជៀសវាងផុតចាកសោក ហើយ ទ្រង់ល្អក្នុងលោក ព្រមទាំងទេវលោក ហើយ ញុំាងសត្វដែលមានសោកឲ្យរីករាយ ខ្ញុំសូមនមស្ការនូវ ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានឆវីវណ្ណដ៏ស្អាត ។*

ភ. ភជិតា យេន សទ្ធម្មា ភគ្គាបេន តាទិនា
ភយសត្តេ បហាសេន្តោ ភយសន្តំ នមាមិហំ ។

*ព្រះសទ្ធម្មទាំងឡាយ ដែលព្រះពុទ្ធជាម្ចាស់អង្គឯណា មានបាបធម្មាយបំបាក់ចោលហើយ មានព្រះហឫទ័យមាំ*

ទ្រង់បែកហើយ ព្រះពុទ្ធជាម្ចាស់អង្គនោះ ទ្រង់ញុំាងសត្វ
ដែលភ័យខ្លាច ឲ្យបាត់ភ័យខ្លាច ខ្ញុំសូមនមស្ការនូវ
ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានភ័យស្ងប់ហើយ ។

គ. គមិតោ យេន សទ្ធម្មោ គមាបិតោ សទេវកំ

គច្ឆមានោ សិវំ រម្មំ គតជម្មំ នមាមិហំ ។

ព្រះសទ្ធម្មទាំងឡាយ ដែលព្រះពុទ្ធជាម្ចាស់អង្គឯណា
ទ្រង់ទម្លុះហើយ ទ្រង់ញុំាងមនុស្ស ព្រមទាំងទេវតា
ឲ្យទម្លុះហើយ ទ្រង់ទម្លុះដល់ព្រះនិព្វាន ជាទីរីករាយ
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមាន
ធម៌ទម្លុះហើយ ។

វា. វានា និក្ខមិ យោ តណ្ហា វាចំ ភាសតិ ឧត្តមំ

វាននិព្វាបនត្ថាយ វាយមន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ចេញចាកវានៈគឺតណ្ហា
ទ្រង់ពោលព្រះវាចាដ៏ឧត្តម ប្រយោជន៍ដល់ការរលត់
នូវតណ្ហា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ
ដែលជាអ្នកមាននូវសេចក្ដីព្យាយាម ។

អ. អនប្បា សកសត្តានំ អនប្បាសំ ទេតិ យោ ជិនោ

អនន្តគុណសម្បន្នោ អន្តគាមី នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រទាននូវភាពកក់ក្ដៅ

ដល់សត្វទាំងឡាយ ដែលមិនមានភាពកក់ក្តៅ ទ្រង់
ដល់ព្រមដោយគុណទាំងឡាយ រកប្រមាណមិនបាន
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលដល់
នូវទីបំផុត (នៃទុក្ខ) ។

រ. រតោ និព្វានសម្បត្តេ    រតោ យោ សត្តមោចនេ
រម្មាបេតីធ សត្តេ យោ    រណាចាគំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរហើយក្នុង
និព្វានសម្បត្តិ ទ្រង់ត្រេកអរក្នុងការញ៉ាំងសត្វឲ្យរួចចាកទុក្ខ
ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ញ៉ាំងសត្វទាំងឡាយក្នុង
លោកនេះ ឲ្យត្រេកអរ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
អង្គនោះ ដែលជាអ្នកលះបង់នូវសត្រូវគឺកិលេស ។

ហំ. ហញ្ញតិ បាបកេ ធម្មេ    ហំសាបេតិ បរំ ជនំ
ហំសមានំ មហាវីរំ    ហន្តបាបំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្លាប់បាបធម៌ជាខាង
ក្នុង ហើយញ៉ាំងជនដទៃឲ្យសម្លាប់បាបធម៌ដែរ ខ្ញុំសូម
នមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកសម្លាប់
នូវបាប ជាមហាវីរៈ កម្ចាត់បាបបាន ។

ស. សង្ខតាសង្ខតេ ធម្មេ    សម្មា ទេសេសិ បាណិនំ
សំសារំ សរិយាជេតិ    សមុត្តណ្ណំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្តែងនូវធម៌ដែលជា
សង្ខត: និងអសង្ខត: ដល់សត្វទាំងឡាយដ៏ប្រពៃ
ទ្រង់ពិឃាតនូវសង្សារវដ្តបានហើយ ខ្ញុំសូមនមស្ការ
នូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាព្រះសម្ពុទ្ធ ។

ម្ចា. មាតាវ បាលិតោ សត្តេ មានច្ឆេទេ បមទ្ទិនោ
មានិតោ ទេវសង្ឃេហិ មានឃាតំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់រក្សានូវសត្វទាំងឡាយ
ដូចមាតារក្សានូវកូន ទ្រង់ញាំញីនូវមាន:ដ៏រឹងត្អឹង ទ្រង់ជា
អ្នក ដែលពួកទេវតាតែងបូជាហើយ ខ្ញុំសូមនមស្ការនូវ
ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកសម្លាប់នូវមាន: ។

ស. សព្វាយំ បារមី សម្មា សញ្ចិត្វា សុខមត្តនោ
សង្ខារានំ ខយំ ទិស្វា សន្តគាមឹ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សន្សំនូវបារមីទាំងឡាយ
ដ៏ប្រពៃ ទ្រង់សុខក្នុងអង្គជាសុខុមល្អិត ខ្ញុំសូមនមស្ការនូវ
ព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកដល់នូវធម៌ដ៏ស្ងប់
ព្រោះឃើញនូវការអស់ទៅនៃសង្ខារទាំងឡាយ ។

ពុ. ពុជ្ឈិត្វា ចតុសច្ចានិ ពុជ្ឈាបេតិ មហាជនំ
ពុជ្ឈាបេន្តំ សិវំ មគ្គំ ពុទ្ធសេដ្ឋំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រាស់ដឹងច្បាស់នូវ

សច្ចៈទាំង ៤ ទ្រង់ញុាំងមហាជនឲ្យត្រាស់ដឹងផង
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធដ៏ប្រសើរអង្គនោះ ដែលជាអ្នក
បង្ហាញសត្វឲ្យដឹងផ្លូវព្រះនិព្វាន ។

ធោ. ធោតិ រាគេ ច ទោសេ ច ធោតិ មោហេ ច ចាណិនំ
ធោតក្លេសំ មហាបុញ្ញំ ធោតាសវំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់លាងនូវរាគៈ ទោសៈ និង
មោហៈជ្រះហើយ ញុាំងសត្វទាំងឡាយឲ្យលាងកិលេស
អស់ហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ
ដែលជាអ្នកមានបុណ្យច្រើន មានអាសវៈលាងហើយ ។

វិ. វិវេចេតិ អសទ្ធម្មា វិចិត្វា ធម្មទេសនំ
វិវេកេ ឋិតចិត្តោ យោ វិទិតន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ឆ្ងាយស្ងាត់ចាកអសទ្ធម្ម
ហើយទ្រង់វិចិត្រនូវធម្មទេសនា តម្កល់ព្រះទ័យក្នុងវិវេក
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជា
អ្នកប្រាជ្ញ ។

ជា. ជាតិធម្មោ ជរាធម្មោ ជាតិអន្តោ បកាសិតោ
ជាតិសេដ្ឋេន ពុទ្ធេន ជាតិមុត្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា មានជាតិជាព្រះពុទ្ធដ៏ប្រសើរ
ហើយទ្រង់ប្រកាសសម្ដែងនូវព្រះនិព្វានជាទីបំផុតនៃជាតិ

គឺជាតិធម៌ និងជរាធម៌ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលរួចផុតចាកជាតិ ។

ច. ចយេតិ បុញ្ញសម្ភារេ    ចយេតិ សុខសម្បទំ

ចជន្តំ ចាបកម្មានិ    ចជាបេន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រកបនូវបុណ្យសម្ភារ ទើបសន្សំបាននូវសុខសម្បទ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលលះបង់នូវបាបកម្មទាំងឡាយ ដោយខ្លួនឯង ហើយញ៉ាំងសត្វឲ្យលះបង់ផង ។

រ. រមិតំ យេន និព្វានំ    រក្ខិតា លោកសម្បទា

រជោសាទិក្លេសេហិ    រហិតំ តំ នមាមិហំ ។

ព្រះនិព្វានដែលព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរហើយ លោកសម្បទាដែលព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់រក្សាទុកហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលវៀរចាកកិលេសទាំងឡាយមានទោសៈជាដើម ។

ណ. នមិតោយេវ ព្រហ្មេហិ    នរទេវេហិ សព្វទា

នទន្តោ សីហនាទំ យោ    នទន្តំ តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់បន្លឺសីហនាទ ជាទីត្រេកអរនៃមនុស្ស ទេវតា និងព្រហ្មទាំងឡាយ តែងថ្វាយបង្គំ

*សព្វកាល ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកបន្លឺសីហនាទ ។*

ស. សង្ខារេ តិវិធេ លោកេ សព្ពានាតិ អនិច្ចតោ

សម្មា និព្វានសម្បត្តិ សម្បន្នោ តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់កំណត់ដឹងនូវសង្ខារទាំងឡាយក្នុងលោកទាំង ៣ ដោយភាពជារបស់មិនទៀង ទ្រង់ដល់ព្រមដោយនិព្វានសម្បត្តិដ៏ប្រពៃ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ។*

ប្ប. បការោ ពោធិសម្ភារេ បសដ្ឋោ យោ សទេវកេ

បញ្ញាយ ន សមោ ហោតិ បសន្នំ តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សាងសន្សំពោធិសម្ភារ ទើបបានជាអ្នកប្រសើរបំផុតក្នុងមនុស្ស ព្រមទាំងទេវតា មិនមានអ្នកស្មើដោយបញ្ញារបស់ព្រះអង្គ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជាអ្នកថ្លៃថ្នូរ ។*

ន្នោ. នោ ទេតិ និរយំ គន្តុំ នោ ច ទាបំ អការយិ

នោ សមោ អត្ថិ បញ្ញាយ នោនជម្មំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ការពារសត្វមិនឲ្យធ្លាក់ទៅនរក និងមិនឲ្យធ្វើអំពើបាប អ្នកណាមួយស្មើដោយបញ្ញារបស់ព្រះអង្គមិនមាន ខ្ញុំសូមនមស្ការនូវព្រះពុទ្ធ*

ជាម្ចាស់អង្គនោះ ជាអ្នកមិនធ្វេសប្រហែស ។

សុ. សុន្ទរោ វរវណ្ណេន សុសរោ ធម្មភាសនេ
សុទ្ទុទ្ទសំ ទិសាបេតិ សុគតំ តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា មានព្រះរូបដ៏ស្អាត ទ្រង់សម្តែងព្រះធម៌ មានសូរសៀងពីរោះក្រៃ ប្រោសវេនេយ្យសត្វឲ្យឃើញធម៌ ដែលឃើញបានដោយលំបាក ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ទ្រង់មានដំណើរយាងទៅល្អហើយ ។

គ. គច្ឆន្តោ លោកិយា ធម្មា គច្ឆន្តោ អមតំ បទំ
គតោ សោ សត្តមោចេតុំ គតញ្ញាណំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ចេញចាកលោកិយធម៌ ដល់នូវបទគឺអមតធម៌ ទ្រង់យាងទៅទីណាៗ ក៏ដើម្បីរំដោះសត្វចាកទុក្ខ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលដល់ហើយនូវសព្វញ្ញុតញ្ញាណ ។

តោ. តោសេន្តោ វរធម្មេន តោសដ្ឋានេ សិវេ វរេ
តោសំ អកាសិ ជន្តូនំ តោសចិត្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ញ៉ាំងសត្វឲ្យរីករាយដោយធម៌ដ៏ប្រសើរ ទ្រង់ធ្វើនូវសេចក្តីត្រេកអរក្នុងព្រះនិព្វាន ដែលជាទីត្រេកអរដល់សត្វទាំងឡាយ

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានព្រះទ័យរីករាយ ។*

លោ. លោកេ ជយាតិ សម្ពុទ្ធោ លោកសេដ្ឋោ គុណាករោ
លោកេ សត្តេ ជហាបេតិ លោកសន្តំ នមាមិហំ ។

*ព្រះសម្ពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ជាអ្នកធ្វើនូវគុណដ៏ប្រសើរក្នុងលោក ទ្រង់លះបង់នូវលោកៈបាន ហើយញុំាងសត្វឲ្យលះបង់នូវលោកៈដែរ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានលោកៈស្ងប់ហើយ ។*

ក. កន្តោ យោ សព្វសត្តានំ កត្វា ទុក្ខក្ខយំ ជិនោ
កថេន្តោ មធុរំ ធម្មំ កថាសណ្ហំ នមាមិហំ ។

*ព្រះពុទ្ធជិនស្រីជាម្ចាស់អង្គឯណា ទ្រង់ជាទីស្រឡាញ់នៃសព្វសត្វទាំងឡាយ ទ្រង់សម្តែងនូវធម៌ដែលមានសំឡេងពីរោះផ្អែម ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានព្រះវាចាដ៏ល្អិតសុខុម ។*

វិ. វិនយំ យោ បកាសេតិ វិត្ថំសេត្វា តយោ ភវេ
វិសេសញ្ញាណសម្បន្នោ វិប្បសន្នំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្តែងនូវព្រះវិន័យ ទ្រង់ទម្លាយនូវត្រៃភពហើយ ទ្រង់ដល់ព្រមដោយព្រះញាណដ៏វិសេស ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*

អង្គនោះ ដែលមានព្រះទ័យថ្លាស្អាតបរិសុទ្ធ ។

ទូ. ទូសេ សន្តេ បហាសេន្តោ ទូរដ្ឋានេ បកាសតិ

ទូរំ និព្វានមាគម្ម ទូសហន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ញុំាំងសត្វអ្នកប្រទូស្តរ៉ាយ
ឲ្យរីករាយបាត់ក្រោធខឹង ដោយព្រះធម៌ ទ្រង់មានកិត្តិគុណ
ប្រាកដទៅឆ្ងាយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គ
នោះ ទ្រង់ដល់ដែនដ៏ឆ្ងាយគឺព្រះនិព្វាន ហើយកម្ចាត់
បង់នូវសេចក្តីអាក្រក់ ។

អ. អន្តំ ជាតិជរាទីនំ អកាសិ ទិបទុត្តមោ

អនេកុស្សាហចិត្តេន អស្សាសេន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រសើរជាងសត្វអ្នក
មានជើងពីរ ទ្រង់ធ្វើទីបំផុតនៃទុក្ខ មានជាតិ និងជរា
ជាដើមហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គ
នោះ ដែលប្រោសសត្វឲ្យរីករាយ ដោយទឹកព្រះទ័យ
គឺឧស្សាហៈដ៏ច្រើន ។

នុ. នុទេតិ រាគចិត្តានិ នុទាបេតិ បរំ ជនំ

នុន អត្តំ មនុស្សានំ នុសាសន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់បន្ទោបង់នូវរាគចិត្ត
បានហើយ ទ្រង់ញុំាំងជនដទៃឲ្យបន្ទោបង់ដែរ ខ្ញុំ

សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់
បង្រៀនធម៌ជាប្រយោជន៍ដល់មនុស្សទាំងឡាយដ៏ពិត
ប្រាកដ ។

ត្ត. តនោតិ កុសលំ កម្មំ   តនោតិ ធម្មទេសនំ
តណ្ហាយ វិចរន្តានំ   តណ្ហាឃាដំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ផ្សព្វផ្សាយនូវធម៌ដែល
ជាកុសល ទ្រង់ពង្រីកការសម្តែងព្រះធម៌ឲ្យទូលាយ
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលជួយ
កម្ចាត់នូវតណ្ហារបស់សត្វទាំងឡាយ ដែលត្រាច់ទៅ
ដោយតណ្ហា ។

រោ. រោសេន្តោ នេវ កោបេតិ   រោសេហេវ ន កុជ្ឈតិ
រោគានំ រាគអាទីនំ   រោគហន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់មិនក្រោធអ្នកដែលក្រោធ
ទ្រង់មិនមានក្រោធសោះ ចំពោះមនុស្សដែលក្រោធ
ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់
កម្ចាត់រោគនៃរោគទាំងឡាយ មានរាគៈជាដើម ។

បុ. បុណាន្តំ អត្តនោ បាបំ   បូរេន្តំ ទសបារមី
បុញ្ញវន្តស្ស រាជស្ស   បុត្តភូតំ នមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់កម្ចាត់បាប

*របស់ព្រះអង្គ ទ្រង់បំពេញហើយនូវបារមី ១០*
*ជាឱរសរបស់ព្រះរាជាអ្នកមានបុណ្យ ។*

វិ. វិបុរាគាធិភូតំ វ   វិទ្ធិយា បដិហញ្ញតិ
វិត្តំ កម្មំ ន ការេតា-   វិយវំសំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់កម្ចាត់នូវវត្ថុដែល*
*ជាសត្រូវ មានរាគៈជាដើម ដោយបុញ្ញឫទ្ធិ ទ្រង់*
*មិនញ៉ាំងសត្វឲ្យធ្វើនូវកម្ម ដែលឥតប្រយោជន៍*
*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែល*
*ជាវង្សព្រះអរិយៈ ។*

ស. សម្បន្នោ វរសីលេន   សមាធិបវរោ ជិនោ
សយម្ភូញាណសម្បន្នោ   សណ្ហវាចំ នមាមិហំ ។

*ព្រះពុទ្ធជិនស្រីជាម្ចាស់អង្គឯណា ទ្រង់ដល់ព្រមដោយ*
*សីលដ៏ប្រសើរ មានសមាធិដ៏ខ្ពង់ខ្ពស់ ប្រកបដោយ*
*សយម្ភូញាណ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គ*
*នោះ ដែលមានព្រះវាចាដ៏ពីរោះ ។*

ទ. ទន្តោ យោ សកចិត្តានិ   ទមិត្វាបិ សទេវកំ
ទទន្តោ អមតំ ខេមំ   ទន្តិន្ទ្រិយំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ទូន្មាននូវចិត្តរបស់អង្គ*
*ឯងហើយ ទ្រង់ទូន្មានសូម្បីនូវមនុស្ស និងទេវតា ហើយ*

ប្រទាននូវអមតធម៌ដ៏ក្សេម ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានឥន្ទ្រិយទូន្មានហើយ ។

ម្ម. មហាសុប្បហោន សម្ពុទ្ធោ មហន្តំ ញាណមាគមិ
មហិតំ នរទេវេហិ មនោសុទ្ធំ នមាមិហំ ។

ព្រះសម្ពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ចាក់ធ្លុះនូវញាណដ៏ធំ ដោយសេចក្តីព្យាយាមដ៏ក្រៃលែង ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានមនោដ៏បរិសុទ្ធ ដែលមនុស្ស ព្រមទាំងទេវតាតែងគោរពបូជា ។

សា. សារំ ទេតីធ សត្តានំ សារេតិ អមតំ បទំ
សារថី វិយ សារេតិ សារធម្មំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រទាននូវធម៌ដ៏ខ្លឹមដល់សត្វទាំងឡាយ ហើយញុំាងសត្វទាំងឡាយឲ្យដល់នូវបទគឺអមតៈ ដូចសារថីញុំាងសេះឲ្យស្ទុះទៅកាន់ទីដែលខ្លួនប្រាថ្នា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានធម៌ជាសារៈ ។

រ. រម្មតារិយសទ្ធម្មេ រម្មាបេតិ សសាវកំ
រម្មេ ឋានេ វសាបេន្តំ រណាហន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរក្នុងអរិយសទ្ធម្ម ទ្រង់ញុំាងសាវករបស់ព្រះអង្គ ឲ្យត្រេកអរផង ខ្ញុំសូម

នមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលញុំាងសាវក
ឲ្យតាំងនៅក្នុងឋានៈដែលគួរត្រេកអរ កម្ចាត់សត្រូវ
គឺកិលេស ។

ឋិ. ឋិតោ យោ វរនិព្វានេ ឋិរេ ឋានេ សសាវកោ
ឋិរំ ឋានំ បកាសេតិ ឋិតំ ធម្មេ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ព្រមទាំងសាវករបស់ព្រះអង្គ
តាំងនៅក្នុងឋានៈដ៏មាំទាំគឺព្រះនិព្វាន ទ្រង់ប្រកាសនូវ
ឋានៈដ៏មាំទាំគឺព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជា
ម្ចាស់អង្គនោះ ដែលតាំងនៅក្នុងធម៌ ។

ស. សទ្ធម្មំ ទេសយិត្វាន សន្តនិព្វានទាយកំ
សសាវកំ សមាហិតំ សន្តចិត្តំ នមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ព្រមទាំងសាវក
របស់ព្រះអង្គ ដែលសម្តែងនូវព្រះសទ្ធម្មឲ្យដល់នូវ
ព្រះនិព្វានដ៏ស្ងប់ ជាអ្នកតាំងមាំ មានចិត្តដ៏ស្ងប់ ។

ដ្ឋា. ឋានំ និព្វានសង្ខាតំ ឋាមេនាធិគតោ មុនិ
ឋានេ សគ្គសិវេ សត្តេ ឋាបេន្តំ តំ នមាមិហំ ។

ព្រះមុនីជាម្ចាស់អង្គឯណា បានចាក់ធ្លុះនូវឋានៈពោល
គឺព្រះនិព្វាន ដោយកម្លាំងគឺសេចក្តីព្យាយាម ខ្ញុំសូម
នមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលញុំាងសត្វ

ឲ្យតាំងនៅក្នុងឋានៈគឺសួគ៌និងនិព្វាន ។

ទេ. ទេន្តោ យោ សគ្គនិព្វានំ ទេវមនុស្សបាណិនំ
ទេន្តំ ធម្មវរំ ទានំ ទេវសេដ្ឋំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ប្រទាននូវសម្បត្តិគឺសួគ៌និងនិព្វាន ដល់ពួកសត្វគឺមនុស្សនិងទេវតា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ជាទេវៈប្រសើរប្រទាននូវធម៌ដ៏ប្រសើរ ។

វ. វន្តរាគំ វន្តទោសំ វន្តមោហំ អនាសវំ
វន្ទិតំ ទេវព្រហ្មេហិ វំ ពុទ្ធំ នមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ ទ្រង់ខ្ជាក់ចេញនូវរាគៈ ខ្ជាក់ចេញនូវទោសៈ ខ្ជាក់ចេញនូវមោហៈ ជាអ្នកមិនមានអាសវៈ ដែលទេវតានិងព្រហ្មទាំងឡាយក្រាបថ្វាយបង្គំហើយ ។

ម. មហតា វីរិយេនាបិ មហន្តំ បារមឹ អកា
មនុស្សទេវព្រហ្មេហិ មហិតន្តំ នមាមិហំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សាងបារមីដ៏ធំធេងដោយសេចក្តីព្យាយាមដ៏ធំ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមនុស្ស ទេវតា និងព្រហ្មទាំងឡាយបូជាហើយ ។

នុ.    នុនធម្មំ បកាសេន្តោ    នុទនត្ថាយ ទាបកំ

នុន ទុក្ខាធិបន្នានំ    នុទាបិតំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់សម្ដែងធម៌ដ៏ពិត ដើម្បីដកចេញនូវបាបរបស់សត្វទាំងឡាយ ដែលជាប់នៅក្នុងទុក្ខ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលប្រោសសត្វឲ្យចេញចាកបាបបាន ។*

ស្សា. សាវកានំនុសាសេតិ    សារធម្មេ ច ទាណិនំ

សារធម្មំ មនុស្សានំ    សាសិតំ តំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់បង្រៀនសារធម៌ដល់សាវ័កទាំងឡាយ និងសត្វទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលបង្រៀនធម៌ជាសារៈដល់មនុស្សទាំងឡាយ ។*

នំ.    នន្ទេន្តោ វរសទ្ធម្មេ    នន្ទាបេតិ មហាមុនិ

នន្ទភូតេហិ ទេវេហិ    នន្ទនីយំ នមាមិហំ ។

*ព្រះមហាមុនីជាម្ចាស់អង្គឯណា ទ្រង់ត្រេកអរក្នុងព្រះសទ្ធម្ម ទ្រង់ញ៉ាំងសត្វទាំឡាយឲ្យត្រេកអរផង ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទេវតាទាំងឡាយជាអ្នកត្រេកអរ គប្បីត្រេកអរក្នុងព្រះអង្គ ។*

ពុ. ពុជ្ឈិត្វារិយសច្ចានិ ពុជ្ឈាបេតិ សទេវកំ

ពុទ្ធញ្ញាណេហិ សម្បន្នំ ពុទ្ធំ សម្មា នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ត្រាស់ដឹងអរិយសច្ច ហើយ ញុំាងមនុស្សនិងទេវតាទាំងឡាយ ឲ្យត្រាស់ ដឹងផង ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលដល់ព្រមដោយពុទ្ធញ្ញាណទាំងឡាយ ត្រាស់ ដឹងដោយប្រពៃហើយ ។*

ទ្ធោ. ធោវិតព្វំ មហាវីរោ ធោវន្តោ មលមត្តនោ

ធោវិតោ ធារណិំ ធាបំ ធោតក្កេសំ នមាមិហំ ។

*ព្រះមហាវីរៈជាម្ចាស់អង្គឯណា ទ្រង់លាងមន្ទិលដែល គប្បីលាងរបស់ព្រះអង្គ ហើយទ្រង់លាងនូវមន្ទិល របស់សត្វទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះមហាវីរៈ ជាម្ចាស់អង្គនោះ ដែលមានគ្រឿងសៅហ្មងលាង ជ្រះហើយ ។*

ភ. ភយមាបន្នសត្តានំ ភយំ ហាបេតិ នាយកោ

ភវេ សត្តេ អតិក្កន្តោ ភយសន្តំ នមាមិហំ ។

*ព្រះនាយកជាម្ចាស់អង្គឯណា ទ្រង់ញុំាងសេចក្តីខ្លាច របស់សត្វទាំងឡាយ ដែលមានខ្លាច ឲ្យវិនាសបាត់ ទៅ ទ្រង់ចូងបាកភពទាំងពួង ខ្ញុំសូមនមស្ការនូវ ព្រះនាយកជាម្ចាស់អង្គនោះ ដែលមានភ័យស្ងប់ហើយ ។*

គ. គហិតោ យេន សទ្ធម្មោ   គតញ្ញាណេន ចាណិនំ

គហាណិយំ វរំ ធម្មំ   គណ្ហាបេន្តំ នមាមិហំ ។

*ព្រះសទ្ធម្មដែលព្រះពុទ្ធជាម្ចាស់អង្គឯណា មានព្រះញាណ ដល់ព្រមត្រាស់ទុកហើយ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់ញ៉ាំងសត្វទាំងឡាយឲ្យទទួលយកនូវធម៌ ដែលគួរទទួលយកដ៏ប្រសើរ ។*

ឃ. ឃាបិតំ បវរំ ធម្មំ   ឃាណមោក្ខាយ ភិក្ខុនំ

ឃាសិតំ បវរេ ធម្មេ   ឃានហន្តំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលទ្រង់បណ្តុះនូវធម៌ដ៏ប្រសើរដល់ភិក្ខុទាំងឡាយ ដើម្បីរួចផុតចាកឃានៈគឺតណ្ហា អប់រំហើយក្នុងធម៌ដ៏ប្រសើរ កម្ចាត់ឃានៈគឺតណ្ហា ។*

ង. ងិណ្ណោ យោ សព្វចាបេហិ   ងិណ្ណោ សគ្គា បតិដ្ឋិតោ

ងិរេ និព្វានសង្ខាតេ   ងិក្ខញាណំ នមាមិហំ ។

*ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ចេញចាកបាបទាំងពួង ហើយចេញចាកស្ថានសួគ៌ ទ្រង់តាំងនៅស៊ប់ក្នុងត្រើយ ពោលគឺព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់អង្គនោះ ដែលមានព្រះញាណចាស់ក្លាហើយ ។*

**ចប់ព្រះពុទ្ធគុណ ៥៦ តែប៉ុណ្ណោះ ៕**

ឆប្បញ្ញាស ពុទ្ធគាថា ពុទ្ធគុណា សុគម្ភិរា
ឯតេសមានុភាវេន សោត្ថិ មេ ហោតុ សព្វទា។

*បទពុទ្ធគាថា មានអត្ថាដ៏ជ្រាលជ្រៅ*
*៥៦ នោះឯងត្រូវ ជាបទគុណនៃព្រះពុទ្ធ។*
*ដោយគុណានុភាព លោកនាថដ៏បរិសុទ្ធ*
*សូមឲ្យបានរួចផុត ចាកទុក្ខទោសគ្រោះចេញឆ្ងាយ។*
*សោត្ថិសុខសួស្តី សុខសិរីជោគទាំងឡាយ*
*រោគភ័យសូមខ្ចាត់ខ្ចាយ សូមមង្គលកើតមានហោង ។*

## ព្រះធម្មគុណ ៣៨

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ-
បស្សិកោ ឱបនេយ្យិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

ស្វាក្ខាតោ ភគវតា ធម្មោ *ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការគឺមគ្គ ៤ ផល ៤ និព្វាន ១ )* សន្ទិដ្ឋិកោ *ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង* អកាលិកោ *ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ* ឯហិបស្សិកោ *ជាធម៌គួរដល់ ឯហិបស្សវិធី គឺថាបើ ព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន* ឱបនយិកោ *ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា* បច្ចត្តំ វេទិតព្វោ វិញ្ញូហិ *ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។*

ស្វា. ស្វាកតន្តំ សិវំ រម្មំ    ស្វាធយំ ធម្មទេសិតំ

ស្វាហុនេយ្យំ បុញ្ញក្ខេត្តំ   ស្វាសកន្តំ   នមាមិហំ ។

ព្រះនិព្វាននោះ ជាគុណជាតគួរត្រេកអរ ដែលព្រះពុទ្ធ
ជាម្ចាស់ទ្រង់បានដល់ល្អហើយ ខ្ញុំសូមនមស្ការនូវព្រះ
ធម៌ជាម្ចាស់នោះ ជាធម៌ដែលព្រះពុទ្ធទ្រង់សម្តែងទុកល្អ
ហើយ ព្រះសង្ឃនាំបន្តមកល្អហើយ គួរបូជាយ៉ាង
ល្អ ជាបុញ្ញក្ខេត្តដ៏ប្រសើរពិត ។

ក្វា. ខាទន្តោ យោ សត្តុចាបំ    ខាយិតោ យោ ច មានុសោ

ខាយន្តំ តិវិធំ លោកំ    ខាយិតន្តំ   នមាមិហំ ។

ព្រះធម៌ឯណា ទំពាស៊ីគឺទម្លាយនូវបាបទាំងពួង
ព្រះធម៌ដ៏ផ្អែមឯណា ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុក
ហើយ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែល
ទំពាស៊ីគឺគ្របសង្កត់នូវលោកទាំងបី ប្រាកដច្បាស់ ។

តោ. តោសេន្តោ សត្តសន្តានំ    តោសេតិ ធម្មទេសនំ

តោសចិត្តំ សមិជ្ឈន្តំ    តោសិតំ  តំ នមាមិហំ ។

ព្រះធម៌ឯណា ញ៉ាំងសត្វឲ្យត្រេកអរ ហើយស្តាប់នូវ
ធម្មទេសនា ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ
ដែលញ៉ាំងសត្វមានចិត្តត្រេកអរក្នុងព្រះធម៌ឲ្យចម្រើន
ឲ្យរីករាយ ។

ភ. ភគ្គរាគោ ភគ្គទោសោ ភគ្គមោហោ អនុត្តរោ
ភគ្គកិលេសសត្តានំ ភគវន្តំ នមាមិហំ។

ព្រះធម៌ឯណា បំបាក់រាគៈ បំបាក់ទោសៈ បំបាក់
មោហៈ រកធម៌ដទៃក្រៃលែងជាងគ្មាន ខ្ញុំសូមនមស្ការ
នូវព្រះធម៌ជាម្ចាស់នោះ ដែលជាទីគោរពសក្ការៈរបស់
សត្វអ្នកមានកិលេសបាក់ហើយ ។

គ. គច្ឆន្តោ រម្មកេ សិវេ គមាបិតោ សទេវកេ
គច្ឆន្តោ ព្រហ្មចរិយេ គច្ឆន្តំ តំ នមាមិហំ ។

ព្រះធម៌ឯណា មានដំណើរទៅកាន់ព្រះនិព្វានដ៏គួរ
រីករាយ ញុំាងមនុស្ស ព្រមទាំងទេវតាឲ្យប្រព្រឹត្ត
នូវព្រហ្មចរិយៈ ដំណើរទៅដល់ព្រះនិព្វាននោះ
ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលមាន
ដំណើរទៅយ៉ាងនោះ ។

វ. វន្តរាគំ វន្តទោសំ វន្តមោហំ វន្តបាបកំ
វន្តំ ពាលមិច្ឆាទីនំ វន្តគន្តំ នមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់ ដែលខ្ជាក់ចេញ
នូវរាគៈ ទោសៈ មោហៈ បាប ល្ងង់ មិច្ឆាទិដ្ឋិ និង
កិលេសជាគ្រឿងចង្រៃ ។

តា.　តារេតិ សព្វសត្តានំ　　តារេសិ ឱរមំតិរំ

តារេន្តំ ឱឃសំសារំ　　តារេន្តំ តំ នមាមិហំ។

*ព្រះធម៌ឯណា ញុំាងសត្វឲ្យឆ្លងចាកសង្សារវដ្ត ឆ្ពោះទៅកាន់ព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលញុំាងសត្វឲ្យឆ្លងចាកឱឃៈបាន ។*

ធ.　ធរមានេបិ សម្ពុទ្ធេ　　ធម្មំ ទេសំ និរន្តរំ

ធរេតិ អមតំ បទំ　　ធរេន្តំ តំ នមាមិហំ ។

*ក៏កាលព្រះសម្ពុទ្ធគង់ធរមាននៅ បានសម្តែងនូវព្រះធម៌អស់កាលជានិច្ច ព្រះធម៌ឯណាទ្រទ្រង់ទុកនូវបទគឺអមតៈ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលទ្រទ្រង់ទុកនូវបទគឺអមតៈ ។*

ម្មោ.　មោហញ្ញោ ទមន្តោ សត្តេ មោហជិតេ អការយិ

មោហជាតេ ធម្មចារី　　មោហជិតំ នមាមិហំ ។

*ព្រះធម៌ឯណា ទូន្មានសត្វទាំងឡាយដែលវង្វេង ធ្វើឲ្យជាអ្នកឈ្នះនូវភាពវង្វេងបាន ញុំាងសត្វអ្នកកើតមកដោយភាពវង្វេង ឲ្យប្រព្រឹត្តនូវធម៌ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលគ្របសង្កត់នូវភាពវង្វេងគឺមោហៈបាន ។*

ស.　សព្វសត្តតមោនុទោ　　សព្វសោកវិនាសកោ

សព្វសត្តហិតក្ករោ　　សព្វសន្តំ នមាមិហំ។

ព្រះធម៌ឯណា បន្ទោបង់នូវភាពងងឹតរបស់សត្វទាំងពួង ញុំាងសេចក្តីសោកទាំងពួង ឲ្យវិនាស ធ្វើនូវប្រយោជន៍ ដល់សត្វទាំងពួង ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលមានសភាពស្ងប់ត្រជាក់ដោយប្រការទាំងពួង ។

ទិ. ទិដ្ឋេ ធម្មេ អនុប្បត្តោ ទិដ្ឋិកង្ខាទយោ លុតោ
ទិដ្ឋី ទ្វាសដ្ឋិ ឆិន្នេត្តា ទិដ្ឋិសន្តំ នមាមិហំ ។

ព្រះធម៌ឯណា អ្នកមានបញ្ញាដល់ហើយតាមលំដាប់ ក្នុងទិដ្ឋធម៌ កាត់នូវទិដ្ឋិ ៦២ បាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ឃើញហើយ ។

ឋិ. ឋិតិសីលសមាចារេ ឋិតិតេរសធុតង្គេ
ឋិតិធម្មេ បតិដ្ឋិតំ ឋិតធម្មំ នមាមិហំ។

ព្រះអរិយៈរមែងតាំងនៅក្នុងឋិតិធម៌គឺធម៌មាំទាំ គឺសីលសមាចារ ដែលជាឋិតិ ក្នុងធុតង្គៈ ១៣ ដែលជាឋិតិ ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលជាគ្រឿងដល់ឋិតិ ។

កោ. កោកានំ រាគំ បីឡេតិ កោធោបិ បដិហញ្ញតិ
កោកានំ បូជិតោ លោកេ កោកានន្តំ នមាមិហំ ។

ព្រះធម៌ឯណា ដែលបៀតបៀននូវរាគៈរបស់សត្វ

ទាំងឡាយ ដែលប្រកាន់យក សូម្បីសេចក្តីក្រោធ
ក៏កម្ចាត់ចេញបាន ជាធម៌ដែលសត្វប្រកាន់យក
បូជាក្នុងលោកនេះ ខ្ញុំសូមនមស្ការនូវព្រះធម៌ជា
ម្ចាស់នោះ ដែលជាទីបំផុតនៃការប្រកាន់យក ។

អ. អគ្គោ សេដ្ឋោ វរធម្មោ អគ្គបញ្ញោ បពុជ្ឈតិ
អគ្គំ ធម្មំ សុនិបុណំ អគ្គន្តំ វ នមាមិហំ។

ព្រះធម៌ជាគុណជាតលើសប្រសើរបំផុត អ្នកមាន
បញ្ញាដ៏ប្រសើរ រមែងត្រាស់ដឹងនូវធម៌ដ៏ប្រសើរ
ល្អិតសុខុមបាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់
នោះ ដែលជាធម៌ដ៏ប្រសើរ ។

កា. ការេន្តោ យោ សិវំ រដ្ឋំ ការេតិ ធម្មចារិយេ
កាតព្វសុសិក្ខាកាមេ ការេន្តន្តំ នមាមិហំ។

ព្រះធម៌ឯណា កាលញុំាងសត្វឲ្យធ្វើសិវរាជ្យគឺព្រះនិព្វាន
រមែងញុំាងអ្នកប្រព្រឹត្តធម្មចរិយា ឲ្យធ្វើ ខ្ញុំសូមនមស្ការ
នូវព្រះធម៌ជាម្ចាស់នោះ ដែលញុំាងសត្វអ្នកប្រាថ្នាក្នុង
ការសិក្សាដ៏ល្អ ដែលខ្លួនគប្បីធ្វើ ឲ្យធ្វើនូវសិវរាជ្យនោះ។

លិ. លិតោ យោ សព្វទុក្ខានិ លិខិតោ បិដកត្តយេ
លិម្បិតេបិ សុវណ្ណេន លិតន្តំបិ នមាមិហំ។

ព្រះធម៌ឯណា បំបាត់នូវទុក្ខទាំងពួង ជាធម៌ចារទុក

*ក្នុងព្រះត្រៃបិដក បិទហើយដោយទឹកមាសដ៏ស្អាត ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលបានបំបាត់នូវទុក្ខពិត ។*

កោ. កោ សន្និសោវ ធម្មេន     កោ ធម្មំ អភិបូជយិ
កោ វិន្ទតិ ធម្មរសំ     កោសល្លន្តំ នមាមិហំ។

*អ្វីស្មើដោយព្រះធម៌ (មានឬ) អ្នកណាបូជាព្រះធម៌ដ៏ក្រៃលែង អ្នកណាបានជួបនូវធម្មរស ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលធ្វើបុគ្គលឲ្យឈ្លាស ។*

ឃ. ឃសតិ ពុទ្ធវចនំ     ឃសតិ ធម្មមុត្តមំ
ឃសតិ សគ្គមោក្ខញ្ច     ឃសតន្តំ នមាមិហំ។

*បណ្ឌិតរមែងស្វែងរកព្រះពុទ្ធវចនៈ រមែងស្វែងរកព្រះធម៌ដ៏ខ្ពង់ខ្ពស់ និងរមែងស្វែងរកនូវសួគ៌និងព្រះនិព្វាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលជាទីស្វែងរកនៃបណ្ឌិត ។*

ហិ. ហិនេ ថានេ ន ជាយន្តេ     ហិនេ ថោមេតិ សុគតឹ
ហិនេ មោហាសមំ ជាលំ     ហិនន្តំបិ នមាមិហំ។

*ព្រះធម៌ឯណា មិនញ៉ាំងសត្វឲ្យកើតក្នុងទីដ៏ថោកទាប ញ៉ាំងមនុស្សទាប (ដែលធ្វើល្អ) ឲ្យរីករាយក្នុងសុគតិ លះសំណាញ់គឺកិលេស ស្មើដោយមោហៈបាន ខ្ញុំសូម*

នមស្ការនូវព្រះធម៌ជាម្ចាស់នោះ ដែលជាទីបំផុតនៃ
ហីនធម៌ ។

ប. បករោ ពោធិសម្ភារេ បសដ្ឋោ យោ សទេវកេ
បញ្ញាយ ន សមោ ហោតិ បសដ្ឋោ តំ នមាមិហំ។

ព្រះធម៌ឯណា ទ្រង់សាងសន្សំពោធិសម្ភារទើបបានជាអ្នក
ប្រសើរបំផុតក្នុងមនុស្ស ព្រមទាំងទេវតា វត្ថុដូរផង់ស្មើ
ដោយបញ្ញាមិនមាន ខ្ញុំសូមនមស្ការនូវព្រះធម៌ជាម្ចាស់
នោះ ។

ស្បិ. សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ សីលធម្មំ នមាមិហំ ។

សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល
សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល
សត្វទាំងឡាយទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានបាន
ក៏ព្រោះសីល ខ្ញុំសូមនមស្ការនូវព្រះធម៌គឺសីលជា
ម្ចាស់នោះ ។

កោ. កោ យោ អគ្គបុញ្ញោ ពុទ្ធោ កោធជហំ អធិគច្ឆតិ
កោធម្មញ្ញូ វិជានាតិ កោធវគ្គំ នមាមិហំ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ជាអ្នកមានបុណ្យដ៏ប្រសើរ
ទ្រង់ត្រាស់ដឹងនូវធម៌ ដែលលះសេចក្តីក្រោធបាន

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ដឹងច្បាស់នូវធម៌ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលខ្ជាក់ចោលនូវសេចក្តីក្រោធបាន ។

ឱ. ឱភតោ សព្វកិលេសំ ឱភញ្ចិតោ សព្វាសវំ

ឱភតោ ទិដ្ឋិជាលញ្ច ឱភតំ តំ នមាមិហំ។

ព្រះធម៌ឯណា ទម្លាយកិលេសទាំងពួងបាន បំបាក់អាសវៈទាំងពួងហើយ និងរើនូវបណ្តាញគឺទិដ្ឋិចេញបានហើយ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលជាគុណជាតរើកិលេសចេញ ។

ប. បញ្ញា បសដ្ឋា លោកស្មឹ បញ្ញា និព្វេធគាមិនី

បញ្ញាយ ន សមោ ហោតិ បសន្នោ តំ នមាមិហំ ។

បញ្ញា ជាគុណជាតិប្រសើរក្នុងលោក បញ្ញាធ្វើឲ្យដឹងច្បាស់ គុណជាតិផូរផង់ស្មើដោយបញ្ញា រមែងមិនមាន ខ្ញុំសូមនមស្ការនូវព្រះធម៌គឺបញ្ញានោះ ។

ន. នរានរហិតំ ធម្មំ នរទេវេហិ បូជិតំ

នរានំ កាមបង្កេហិ នមិតន្តំ នមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះធម៌ ដែលជាប្រយោជន៍ដល់មនុស្ស និងអមនុស្ស ដែលមនុស្ស និងទេវតាទាំងឡាយ តែងបូជា ញុំាងមនុស្សទាំងឡាយ ឲ្យផុតចាករណ្តៅគឺកាមនោះ ។

យិ.   យិដ្ឋតេ សព្វសត្តានំ   យិដ្ឋតេ ទេវព្រហ្មុនា
យិដ្ឋិស្សតេ ច ចាណីហិ   យិដ្ឋន្តម្បិ នមាមិហំ ។

*ព្រះធម៌ឯណា ដែលសត្វទាំងពួងទាំងឡាយ តែងបូជា ទេវតានិងព្រហ្មក៏បូជា សត្វទាំងឡាយនឹងបូជាតៗទៅ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលសត្វទាំងឡាយ តែងបូជា ។*

កោ.   កោធំ ជហាតិ ចាបកំ   កោធកោធញ្ញូ នាស្សតិ
កោធំ ជហោតិ ធម្មេន   កោធន្ទុំ នមាមិហំ ។

*ព្រះធម៌ឯណា លះសេចក្តីក្រោធដ៏លាមកបាន និងធ្វើ មនុស្សមានសេចក្តីក្រោធ ឲ្យបាត់ក្រោធ សត្វលះ សេចក្តីក្រោធបានដោយធម៌ ខ្ញុំសូមនមស្ការនូវ ព្រះធម៌ ដែលបន្ទោបង់នូវសេចក្តីក្រោធបាន ។*

ប.   បបញ្ចាភិរតា បជា   បជហិតា ចាបកា ចយោ
បប្បោតិ សោតិវិបុលោ   បជ្ជោតន្តំ នមាមិហំ ។

*ពួកសត្វត្រេកអរក្រៃលែងក្នុងបបញ្ចធម៌ (គឺតណ្ហា មានះ និងទិដ្ឋិ) បាបធម៌ទាំងឡាយនោះ ដែលធម៌ ណាលះបានហើយ អ្នកណាបានដល់ធម៌នោះ អ្នក នោះ ជាវិបុលដ៏ធំទូលាយ ខ្ញុំសូមនមស្ការនូវ ព្រះធម៌នោះ ដែលមានរស្មីពន្លឺច្បាស់ ។*

ចុ. ចរិត្វា ព្រហ្មចរិយំ ចត្តាសវោ វិសុជ្ឈតិ
ចជាបេន្តំ វ ទានេន ចជន្តន្តំ នមាមិហំ ។

*បុគ្គលលះអាសវៈបាន ព្រោះប្រព្រឹត្តព្រហ្មចរិយៈ រមែងបរិសុទ្ធ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលជាសភាពលះ ញុំាងសត្វឲ្យលះដោយការឲ្យទាន ។*

តំ. តនោតិ កុសលំ កម្មំ តនោតិ សព្វវីរិយំ
តនោតិ សីលសមាធី តនន្តំ វ នមាមិហំ ។

*ព្រះធម៌ឯណា ផ្សាយនូវកុសលកម្ម ពង្រីកនូវសេចក្តីព្យាយាម ដើម្បីលះបាប ផ្សាយសីល សមាធិ (និងបញ្ញា) ឲ្យចេញទៅ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលផ្សាយចេញទៅ មិនមានការបិទបាំង ។*

វេ. វេរានិបិ ន ពន្ធន្តិ វេរំ តេសូបសម្មតិ
វេរំ វេរេន វេរានិ វេរសន្តំ នមាមិហំ ។

*នរជនណាមិនចងពៀរទុក ពៀររមែងស្ងប់រម្ងាប់ទៅ ពៀររមែងប្រព្រឹត្តទៅ ព្រោះការចងពៀរ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលស្ងប់នូវពៀរ ។*

ទិ. ទីឃាយុកោ ពហុបុញ្ញោ ទីឃរត្តំ មហព្វលោ
ទីឃសុខេន បុញ្ញេន ទីឃរត្តំ នមាមិហំ ។

*ព្រះធម៌ជាសភាពមានអាយុវែង មានបុណ្យច្រើន មាន*

កម្លាំងខ្លាំង អស់កាលជាអង្វែង ខ្ញុំសូមនមស្ការនូវ
ព្រះធម៌នោះ ដែលអស់កាលជាអង្វែង ដោយបុណ្យ
ឲ្យកើតសុខជាយូរអង្វែង ។

ត. តតោ ទុក្ខា បមុញ្ចន្តោ   តតោ មោចេតិ បាណិនោ
តតោ រាគាទិក្លេសេហិ   តតោ មោក្ខំ នមាមិហំ ។

ព្រះធម៌ឯណា ជាធម៌នាំឲ្យរួចផុតចាកទុក្ខ ញុំាងសត្វឲ្យ
រួចផុតចាកទុក្ខនោះ ចាកកិលេសទាំងឡាយ មានរាគៈ
ជាដើម ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលរួចផុត
ចាកកិលេស និងទុក្ខនោះ ។

ពោ. ពោធី វិជ្ជា ឧបាគមិ   ពោធេតិ មគ្គផលានិ ច
ពោធិយា សត្វធម្មានំ   ពោធិយន្តំ នមាមិហំ ។

វិជ្ជា ចូលដល់នូវការត្រាស់ដឹង ញុំាងសត្វឲ្យត្រាស់ដឹង
នូវមគ្គផលផង ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែល
ជាគ្រឿងត្រាស់ដឹង ដោយត្រាស់ដឹងនូវញេយ្យធម៌
ទាំងពួង ។

វិ. វិរតិ សព្វទុក្ខស្មា   វិរិយេនេវ ទុល្លភា
វិរិយាតាបសម្បន្នា   វិរតន្តំ នមាមិហំ ។

ការវៀរចាកទុក្ខទាំងពួង នឹងមានបានដោយសេចក្ដី
ព្យាយាមប៉ុណ្ណោះ បុគ្គលអ្នកដល់ព្រមដោយសេចក្ដី

*ព្យាយាមដុតកម្តៅកិលេស រកបានដោយកម្រ ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលវៀរចាកទុក្ខ ។*

ញា. ញាតញ្ញាណោហិ សម្បន្នំ ញាតយោគសមប្បិតំ
ញាតញ្ញាណាទស្សនញ្ញា ញាតយោគំ នមាមិហំ ។

*ខ្ញុំសូមនមស្ការនូវព្រះធម៌ ដែលដល់ព្រមដោយសព្វញ្ញុតញ្ញាណ ដែលបរិបូណ៌ដោយយោគៈគឺសេចក្តីព្យាយាមប្រកប ដើម្បីញាណនោះ ខ្ញុំសូមនមស្ការនូវព្រះធម៌គឺសេចក្តីដឹងច្បាស់ និងសេចក្តីព្យាយាមនោះ ។*

ហី. ហីសន្តិ សព្វទោសានិ ហីសន្តិ សព្វភយានិ ច
ហីសមោហា បដិស្សុតា ហីសន្តន្តំ នមាមិហំ ។

*អ្នកមានសតិ បៀតបៀននូវទោសៈទាំងពួងបាន បៀតបៀនភ័យទាំងពួង ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលបៀតបៀននូវទោសៈ និងភ័យ ។*

តិ. តិណ្ណោ យោ វដ្ដទុក្ខម្ហា តិណ្ណំ លោកានមុត្តមោ
តិស្សោ ភូមី អតិក្កន្តោ តិណ្ណាឱឃំ នមាមិហំ ។

*ព្រះធម៌ឯណា ឆ្លងចាកទុក្ខក្នុងវដ្តៈទាំង ៣ ភូមិទាំង ៣ ហើយប្រសើរឧត្តម ខ្ញុំសូមនមស្ការនូវព្រះធម៌នោះ ដែលបានឆ្លងឱឃៈហើយ ។*

**ចប់ព្រះធម្មគុណ ៣៨ តែប៉ុណ្ណោះ ៕**

អដ្ឋត្តឹស ធម្មគាថា ធម្មគុណា សុគន្ធិកា
ឯតេសមានុភាវេន សោត្ថិ មេ ហោតុ សព្វទា។

បទធម្មគាថា មានអត្ថាដ៏ជ្រាលជ្រៅ
៣៨ នោះឯងត្រូវ ធម្មគុណនៃព្រះពុទ្ធ។
ដោយគុណានុភាព ធម្មធាតុដ៏បរិសុទ្ធ
សូមឲ្យបានរួចផុត ចាកទុក្ខទោសគ្រោះចេញឆ្ងាយ។
សោត្ថិសុខសួស្តី សុខសិរីជោគទាំងឡាយ
រោគភ័យសូមខ្ចាត់ខ្ចាយ សូមមង្គលកើតមានហោង។

## ព្រះសង្ឃគុណ ១៤

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃ ជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។

សុ. សុទ្ធសីលេន សម្បន្នោ សុដ្ឋុ យោ បដិបន្នកោ
សុគុណោ សាសនករោ សុគុណន្តំ នមាមិហំ ។

ព្រះសង្ឃឯណា ដល់ព្រមដោយសីលដ៏បរិសុទ្ធ ជាអ្នកបដិបត្តិដ៏ល្អ ជាអ្នកធ្វើតាមពាក្យបង្រៀនដ៏ល្អ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលជាអ្នកដ៏ល្អ ។

ប. បដិសម្ភិទប្បត្តោ យោ បសត្ថោ វ អនុត្តរោ
បញ្ញាយ ឧត្តរោ លោកេ បសត្ថន្តំ នមាមិហំ ។

ព្រះសង្ឃឯណា ជាអ្នកសម្រេចនូវបដិសម្ភិទា ដែលបណ្ឌិតសរសើរហើយដោយពិត ជាអ្នកប្រសើរដោយបញ្ញា ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលប្រសើរក្នុងលោក ។

ដិ. តិត្ថករជិតោ សង្ឃោ តិត្ថោ ធីរោ វ សាសនេ
តិត្តិយា ពុទ្ធវចនេ តិត្តន្តំបិ នមាមិហំ ។

ព្រះសង្ឃឯណា ឈ្មោះលទ្ធិផ្សេងៗ ជាគ្រូអ្នកមានបញ្ញា ក្នុងសាសនាពិត ជាកំពង់ក្នុងព្រះពុទ្ធវចនៈ ខ្ញុំសូម នមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ទុកដូចជាកំពង់។

ប. បសន្នោ ធម្មគម្ភីរោ  បញ្ញវា ច អវង្កតោ
បសត្ថោ អត្ថធម្មញ្ញូ  បសង្ឃំបិ នមាមិហំ ។

ព្រះសង្ឃឯណា ទ្រទ្រង់នូវធម៌ដ៏ជ្រៅ គួរឲ្យសរសើរ មានប្រាជ្ញានិងស្មោះត្រង់ ឃើញអត្ថ ឃើញធម៌ ខ្ញុំ សូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលគួរ សរសើរដោយពិត ។

ន្មោ. នោ ចេតិ កុសលំ កម្មំ  នោ ច បាបំ អការយិ
នោនតំ ពុជ្ឈតិ ធម្មំ  នោទិសង្ឃំ នមាមិហំ ។

ព្រះសង្ឃឯណា មិនធ្វើនូវអំពើជាកុសល និងមិនធ្វើ នូវបាប គឺលះទាំងបុណ្យទាំងបាប ដឹងនូវធម៌ដែល មិនគ្រោតគ្រាត ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់ នោះ ដែលមិនមានសត្រូវជាមួយអ្នកណា ។

ភ. ភគ្គរាគោ ភគ្គទោសោ  ភគ្គមោហោ ច បាណិនំ
ភញ្ជកោ សព្វក្លេសានំ  ភញ្ជនង្ឃំ នមាមិហំ។

ព្រះសង្ឃឯណា ជាអ្នកបំបាក់រាគៈ បំបាក់ទោសៈ បំបាក់មោហៈ និងជួយបំបាក់កិលេសទាំងពួងរបស់

សត្វទាំងឡាយ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់
នោះ ដែលមានកិលេសបំបាក់ហើយ ។

គ. គច្ឆន្តោ លោកិយំ ធម្មំ គច្ឆន្តោ លោកុត្តរម្បិ
គតោយេវ កិលេសេហិ គមិតន្តំ នមាមិហំ ។

ព្រះសង្ឃឯណា កាលដល់លោកិយធម៌ និងលោកុត្តរធម៌ ជាអ្នកចេញចាកគ្រឿងសៅហ្មងទាំងឡាយ ហើយទៅ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលចេញចាក គ្រឿងសៅហ្មងហើយ ។

វ. វណ្ណេតិ កុសលំ ធម្មំ វណ្ណេតិ សីលសម្បទំ
វណ្ណេតិ សីលរក្ខិតំ វណ្ណិតន្តំ នមាមិហំ ។

ព្រះសង្ឃឯណា សរសើរកុសលធម៌ សរសើរការដល់ព្រមនៃសីល សរសើរអ្នករក្សាសីល ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលសរសើរនូវធម៌គួរសរសើរ។

តោ. តោសេន្តោ ទេវមនុស្សេ តោសេន្តោ ធម្មទេសយិ
តោសេតិ ទុដ្ឋចិត្តេបិ តោសេន្តន្តំ នមាមិហំ ។

ព្រះសង្ឃឯណា ញ៉ាំងទេវតានិងមនុស្សទាំងឡាយ ឲ្យត្រេកអរក្នុងធម៌ សម្តែងធម៌គួរពេញចិត្តដល់អ្នកស្តាប់ ញ៉ាំងមនុស្សសូម្បីមានចិត្តប្រទូស្ត ឲ្យត្រឡប់ត្រេកអរ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលញ៉ាំង ទេវតានិងមនុស្សឲ្យត្រេកអរ ។

សា. សាសនំ សម្បដិច្ឆន្តោ    សាសន្តោ សិវគាមិនឹ

សាសនមនុសាសន្តោ    សាសនន្តំ នមាមិហំ ។

ព្រះសង្ឃឯណា ទទួលនូវព្រះសាសនាទុក ណែនាំនូវផ្លូវទៅព្រះនិព្វាន បង្រៀននូវព្រះសាសនា (ដល់មនុស្ស និងទេវតា) ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលណែនាំបង្រៀន ។

វ. វន្តរាគំ វន្តទោសំ    វន្តមោហំ សុទិដ្ឋិកំ

វន្តញ្ច សព្វធាធានិ    វន្តក្លេសំ នមាមិហំ ។

ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់ ដែលមានសេចក្តីឃើញដោយប្រពៃ ខ្ជាក់ចោលនូវរាគៈ ទោសៈ មោហៈ និងកិលេសបាបធម៌ទាំងពួង ។

ក. ការោន្តោ សីលសមាធឹ    ការោន្តោ សារមត្តនោ

ការោន្តោ កម្មដ្ឋានានិ    ការោន្តន្តំ នមាមិហំ ។

ព្រះសង្ឃឯណា បំពេញនូវសីល សមាធិ ធ្វើសារៈដល់ខ្លួន ធ្វើនូវកម្មដ្ឋានផ្សេងៗ ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលជាអ្នកធ្វើ ។

សំ. សំសារេ សំសរន្តានំ    សំសារតោ វិមុត្តិ សោ

សំសារទុក្ខា មោចេសិ    សំសុទ្ធន្តំ នមាមិហំ ។

កាលសត្វទាំងឡាយ កំពុងត្រាច់ចរក្នុងសង្សារវដ្ត ព្រះសង្ឃរួចផុតចាកសង្សារវដ្តហើយ ហើយជួយ

សត្វទាំងឡាយ ឲ្យរួចផុតចាកសង្សារវដ្តផងដែរ
ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលជា
អ្នកបរិសុទ្ធព្រម ៕

យោ. យោ រតុក្ខក្ខយំ កត្វា យោ សាបេតិ សុរំ នរំ
យោ សយិ បិដកត្តយំ យោ សង្ឃំ នមាមិហំ ។

ព្រះសង្ឃឯណា ធ្វើនូវការអស់ទៅនៃទុក្ខដែលគួរឲ្យខ្លាច
ហើយញុំាងមនុស្ស និងទេវតាឲ្យប្រកាសព្រះត្រៃបិដក
ខ្ញុំសូមនមស្ការនូវព្រះសង្ឃជាម្ចាស់នោះ ដែលជាអ្នក
ប្រកាស (នូវព្រះត្រៃបិដក) ៕

**ចប់ព្រះសង្ឃគុណ ១៤ តែប៉ុណ្ណោះ ៕**

ចតុទ្ទស សង្ឃគាថា សង្ឃគុណា សុគម្ភិរា
ឯតេសមានុភាវេន សោត្ថិ មេ ហោតុ សព្វទា ។

បទសង្ឃគាថា មានអត្ថាដ៏ជ្រាលជ្រៅ
១៤ នោះឯងត្រូវ សង្ឃគុណដ៏ហ្មត់ចត់៕
ដោយគុណានុភាព សង្ឃទាយាទដ៏បរិសុទ្ធ
សូមឲ្យបានរួចផុត ចាកទុក្ខទោសគ្រោះចេញឆ្ងាយ៕
សោត្ថិសុខសួស្តី សុខសិរីជោគទាំងឡាយ
រោគភ័យសូមខ្វាត់ខ្វាយ សូមមង្គលកើតមានហោង៕

ឥតិបិសោរតនមាលា និដ្ឋិតា ។

# នមក្ការបាលី-ប្រែ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

*កិរិយានមស្ការថ្វាយបង្គំ (នៃខ្ញុំព្រះករុណា) ចូរមានដល់ព្រះដ៏មាន ព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវ ញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។*

[១] សុគតំ សុគតំ សេដ្ឋំ កុសលំកុសលំ ជហំ

អមតំ អមតំ សន្តំ អសមំ អសមំ ទទំ។

[២] សរណំ សរណំ លោកំ អរណំ អរណំ ករំ

អភយំ អភយំ ឋានំ នាយកំ នាយកំ នមេ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់ស្ដេចយាងទៅ ដ៏ល្អ ទ្រង់ត្រាស់ដ៏ល្អ ទ្រង់ជាអ្នកដ៏ប្រសើរ ទ្រង់លះ នូវកុសល និងអកុសល ទ្រង់វៀរចាកសេចក្ដីស្លាប់ ទ្រង់ទម្លុះដល់អមតនិព្វាន ទ្រង់ជាអ្នកស្ងប់ មិនមាន អ្នកណាមួយ ស្មើដោយព្រះអង្គ ទ្រង់ប្រទាននូវវត្ថុ ដែលគ្មានអ្វីដូច ទ្រង់ជាទីពឹង ទ្រង់ជាទីរឭករបស់ សត្វលោក ទ្រង់មិនមានកិលេស ទ្រង់ធ្វើភាពមិន មានកិលេស ទ្រង់មិនមានភ័យ ទ្រង់នាំទៅកាន់ឋានៈ មិនមានភ័យ ទ្រង់នាំសត្វទៅកាន់ព្រះនិព្វាន ។*

[៣] នយនសុភគកាយង្គំ

មធុរវរសរោបេតំ

អមិតគុណគណាធារំ

ទសពលមតុលំ វន្ទេ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ទ្រង់មានអង្គនៃព្រះវរកាយដ៏ស្រស់
ស្អាត មានព្រះសូរសៀងដ៏ពីរោះ
គួរស្តាប់ ទ្រទ្រង់ទុកនូវគុណរាប់
ប្រមាណមិនបាន មានកម្លាំង ១០
ប្រការ មិនមានអ្នកណាដូច ។

[៤] យោ ពុទ្ធោ ធិតិមាញ្ញធារកោ

សំសារេ អនុភោសិ កាយិកំ

ទុក្ខំ ចេតសិកញ្ច លោកតោ

តំ វន្ទេ នរទេវមង្គលំ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់
មានសមាធិ ទ្រទ្រង់នូវអរហត្តផល
ទ្រង់ប្រសព្វទុក្ខក្នុងសង្សារវដ្ត ព្រោះ

*តែសត្វលោក ខ្ញុំសូមនមស្ការនូវ*
*ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់ជាមង្គល*
*របស់មនុស្សនិងទេវតា ។*

[៥] ពាត្តឹសតិលក្ខណាចិត្រទេហំ

ទេហជ្ជុតិនិគ្គតបជ្ជលគ្គំ

បញ្ញាធិតិសីលគុណោឃវិន្ធំ

វន្ទេ មុនិមន្តិមជាតិយុត្តំ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*
*ដែលមានព្រះវរកាយដ៏ស្រស់ស្អាត*
*ដោយព្រះលក្ខណៈ ៣២ ប្រការ*
*មានព្រះរស្មីដ៏រុងរឿង ផ្សាយចេញ*
*ពីព្រះវរកាយ ទ្រង់បាននូវពួកនៃ*
*គុណ គឺបញ្ញា សមាធិ សីល*
*ទ្រង់ជាព្រះមុនី មានព្រះជាតិចុង*
*ក្រោយបំផុត។*

[៦] ចាតោទយំ ពាលទិវាករំវ

មជ្ឈេ យតីនំ លលិតំ សិរីហិ

បុណ្ណិន្ទុសង្កាសមុខំ អនេជំ
វន្ទាមិ សព្វញ្ញុមហំ មុនិន្ទំ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*
*ប្រៀបដូចដួងអាទិត្យមានរស្មីឧទ័យ*
*រះពេលព្រលឹម ទ្រង់វិលាសដោយ*
*ព្រះសិរីទាំងឡាយ ក្នុងកណ្ដាលនៃ*
*ពួកភិក្ខុ មានព្រះភក្ត្រដូចព្រះចន្ទពេញ*
*វង់ ទ្រង់ប្រាសចាកតណ្ហា ទ្រង់ដឹងសព្វ*
*គ្មានសល់ចន្លោះ ជាព្រះមុនិន្ទ ។*

[៧] ឧបេតបុញ្ញោ វរពោធិមូលេ
សសេនមារំ សុគតោ ជិនិត្វា
អពោជ្ឈិ ពោធឹ អរុណោទយម្ហិ
នមាមិ តំ មារជិនំ អភគ្គំ។

*ព្រះសុគតជាម្ចាស់អង្គឯណា*
*ទ្រង់សម្បូរណ៍ដោយបុញ្ញាធិការ*
*ទ្រង់ឈ្នះមារាធិរាជ ព្រមទាំងសេនា*
*ក្នុងគល់ពោធិព្រឹក្ស បានត្រាស់*
*ដឹងនូវពោធិញ្ញាណ ក្នុងពេល*

*អរុណារះ ខ្ញុំសូមនមស្ការនូវព្រះ*
*សុគតជាម្ចាស់អង្គនោះ ទ្រង់*
*ឈ្នះមារហើយ ដែលមារបំបាក់*
*មិនបាន ។*

[៨] រាគាទិឆេទាមលញាណខគ្គំ

សតីសមញ្ញាផលកាភិកាហំ

សីលោឃលង្ការវិភូសិតំ តំ

នមាមិភិញ្ញាវរមិទ្ធុបេតំ ។

*ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់*
*ទ្រង់កាន់នូវព្រះខ័ន គឺព្រះញាណ*
*កាត់នូវមន្ទិលគឺកិលេស មានរាគៈ*
*ជាដើម ទ្រង់កាន់នូវខែល ឈ្មោះ*
*ថា សតិយ៉ាងមាំ ទ្រង់ប្រដាប់ដោយ*
*គ្រឿងប្រដាប់ គឺសីល ។*

[៩] ទយាលយំ សព្វធិ ទុក្ករំ ការំ

ភវណ្ណវាតិក្កមមគ្គតំ គតំ

តិលោកនាថំ សុសមាហិតំ ហិតំ

សមន្តចក្ខុំ បណមាមិ តំមិតំ ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់មហាករុណាគុណ ទ្រង់ធ្វើនូវវត្ថុដែលធ្វើដោយកម្រ គ្រប់ៗអត្តភាព កន្លងផុតមហោស្រព គឺ កព ទ្រង់ដល់នូវការៈដ៏ប្រសើរ ទ្រង់ជាទីពឹងរបស់លោកទាំង ៣ ទ្រង់មានសមាធិល្អ ទទ្រង់សមាធិដ៏ល្អ ទទ្រង់នូវប្រយោជន៍ ទ្រង់មានសមន្តចក្ខុ មានព្រះគុណ មិនអាចកំណត់បាន ។

[១០] តហឹ តហឹ បារមិសញ្ចយំ ចយំ

គតំ គតំ សត្ថិ សុខប្បទំ បទំ

ចរាចរានំ សុខសម្ភវំ ភវំ

នមាមហំ ជិនបុង្គវំ គវំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់ជាទីប្រជុំនៃបារមី ទ្រង់កសាងបារមីក្នុងអត្តភាពនោះៗ ទ្រង់ជាអ្នកដែលសប្បុរសចូលមករក

ទ្រង់ដល់នូវព្រះនិព្វាន ដែលជាទី
តាំងនៃសេចក្ដីសុខ ញុំាងហេតុនៃ
សុខឲ្យកើតដល់មនុស្ស និងទេវតា
ទ្រង់ជាព្រះជិនស្រីដ៏ប្រសើរខ្ពង់ខ្ពស់
ជាងសត្វទាំងឡាយ ។

[១១] មគ្គង្គនាវំ មុនិទក្ខនាវិកោ
ឦហាជិយំ ញាណករេន គាហកោ
អារុយ្ហ យោ តាយ ពហូ ភវណ្ណវា
តារេសិ តំ ពុទ្ធមយប្បហំ នមេ។

នាយទូកដ៏ឈ្លាស គឺព្រះពុទ្ធជាម្ចាស់
អង្គឯណា ទ្រង់ឡើងកាន់នាវា គឺ
អរិយមគ្គប្រកបដោយអង្គ ៨ ទ្រង់
ប្រើព្រះហស្ត គឺញាណចាប់ច្រវា គឺ
វិរិយៈ នាំវេនេយ្យសត្វដ៏ច្រើន ឆ្លង
ចាកមហោស្រព គឺភព ដោយទូក
គឺមគ្គមានអង្គ ៨ នោះ ទ្រង់ជួយ
កម្ចាត់ទុក្ខឲ្យសព្វសត្វ ។

[១២] សមតឹសតិចារមិសម្ភារណំ

វរពោធិទុមេ ចតុសច្ចសំ
វរមិទ្ធិគតំ នរទេវហិតំ
តិភវូបសមំ បណមាមិ ជិនំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ទ្រង់បំពេញបុណ្យបារមី ៣០ យ៉ាង
បរិបូណ៌ ទ្រង់ត្រាស់ដឹងនូវសច្ចៈទាំង
៤ ទៀបគល់ពោធិព្រឹក្សដ៏ប្រសើរ
ទ្រង់បានសម្រេចនូវឫទ្ធិដ៏ប្រសើរ
ទ្រទ្រង់ទុកនូវប្រយោជន៍របស់
មនុស្សនិងទេវតា ទ្រង់ស្ងប់នូវ
ភពទាំង ៣ ទ្រង់ឈ្នះមារ ។

[១៣]សតបុញ្ញជលក្ខណិកំ វិរជំ
គគនូបមធឹ ធិតិមេរុសមំ
ជលជូបមសីតលសីលយុតំ
បថវីសហនំ បណមាមិ ជិនំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ដែលសម្បូរណ៍ដោយព្រះលក្ខណៈ

ដែលកើតដោយតេជះនៃបុណ្យបារមី
មួយរយ ទ្រង់ប្រាសចាកធូលី គឺ
កិលេស ទ្រង់មានព្រះសព្វញ្ញុតញ្ញាណ
ដូចផ្ទៃនភាកាស មានសមាធិមិនញាប់
ញ័រ ដូចភ្នំសិនេរុ ប្រកបដោយសីល
ដ៏ត្រជាក់ ដូចផ្កាបទុម ដែលកើតក្នុង
ទឹក មានព្រះខន្តិគុណដូចផែនដី ទ្រង់
ឈ្នះមារហើយ ។

[១៤]យោ ពុទ្ធោ សុមតិ ទិវេ ទិវាករោវ

សោភន្តោ រតិជននេ សិលាសនម្ហិ

អាសីនោ សិវសុខទំ អទេសិ ធម្មំ

ទេវានំ តមសទិសំ នមាមិ និច្ចំ ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់មាន
សព្វញ្ញុតញ្ញាណដ៏ល្អ រុងរឿងដូច
ទិវាករក្នុងកណ្ដាលថ្ងៃ គង់លើ
សិលាសនៈ ញ៉ាំងសេចក្ដីត្រេកអរ
ឲ្យកើត សម្ដែងធម៌ប្រទាននិព្វានសុខ
ដល់ពួកទេវតាទាំងឡាយ (ក្នុងស្ថាន

តាវត្តិង្ស) ខ្ញុំសូមនមស្ការនូវព្រះពុទ្ធ
ជាម្ចាស់នោះ គ្មានបុគ្គលណាប្រៀប
ផ្ទឹមពុំបាន ។

[១៥]យោ បាទបង្កជមុទុត្តលរាជិកេហិ

លោកេហិ តីហិវិកលេហិ និរាកុលេហិ

សម្បាបុណេ និរុបមេយ្យតមេវ នាថោ

តំ សព្វលោកមហិតំ អសមំ នមាមិ។

ព្រះពុទ្ធជាម្ចាស់អង្គឯណា ទ្រង់ជាទីពឹង
របស់សព្វសត្វ ទ្រង់ដល់ព្រមដោយភាព
ដែលលោកទាំង ៣ ប្រៀបផ្ទឹមពុំបាន មាន
ព្រះបាទទាំងគូរាបស្មើល្អ មិនវិកល មិន
វិការ ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់
ដែលសត្វលោកទាំងពួងបូជា គ្មានបុគ្គល
ណាប្រៀបបាន ។

[១៦]ពុទ្ធំ នរានរសមោសរណំ ជិនត្តំ

បញ្ញាបទីបជុតិយា វិហតន្ធការំ

អត្ថាភិកាមនរទេវហិតាវហំ តំ

វន្ទាមិ ការុណិកមគ្គមនន្តញាណំ។

ខ្ញុំសូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់
ជាទីដែលមនុស្សនិងទេវតាមកប្រជុំ មាន
ព្រះទ័យមាំទាំ ទ្រង់កម្ចាត់នូវងងឹត ដោយ
ពន្លឺ គឺអរហត្តមគ្គញ្ញាណ ប្រាថ្នាប្រយោជន៍
ដល់សត្វលោក ទ្រទ្រង់ទុកនូវប្រយោជន៍
ដល់មនុស្សនិងទេវតា ទ្រង់មហាករុណា
ដ៏លើស មានព្រះញាណកំណត់មិនបាន។

[១៧] អខិលគុណានិធានោ យោ មុនិន្ទោ បគន្ត្វា
វនមិសិបតនវ្ហំ សញ្ញតានំ និកេតំ
តហិមកុសលជេនំ ធម្មចក្កំ បវត្តោ
តមតុលមភិកន្តំ វន្ទេយ្យំ នមាមិ។

ព្រះមុនីជាម្ចាស់អង្គឯណា ទ្រង់មាន
ព្រះគុណទាំងពួង ទ្រង់យាងទៅព្រៃ
ឥសិបតនៈដែលជាទីនៅរបស់ពួក
ឥសីដែលសង្រួមហើយ ទ្រង់ប្រកាស
ធម្មចក្កដែលជាធម៌កាត់អកុសល ក្នុង
ព្រៃនោះ ខ្ញុំសូមនមស្ការនូវព្រះមុនិន្ទ
ជាម្ចាស់នោះ ដែលមិនមានបុគ្គលណា
ដូច ដែលមនុស្សនិងទេវតាគប្បីចូលរក
ដែលគួរដល់ការថ្វាយបង្គំ ។

[១៨]សុចិបរិវារិតំ សុរុចិរប្បភាហិ រត្តំ
សិរិវិសាលាលយំ គុបិតមិន្ទ្រិយេហុបេតំ
រវិសសិមណ្ឌលប្បកុតិលក្ខណោបចិត្តំ
សុរនរបូជិតំ សុគតមាគរំ នមាមិ។

*ខ្ញុំសូមនមស្ការនូវព្រះសុគតជាម្ចាស់ ដែលមានសាវកចោមរោមហើយ មាន ព្រះវរកាយរុងរឿងដោយរស្មីដ៏ស្រស់ ស្អាត ជាទីរងទទួលពួកនៃព្រះសិរី គឺ បញ្ញានិងបុញ្ញាធិការ ទ្រង់គ្រប់គ្រងឥន្ទ្រិយ មានព្រះបាទប្រដាប់ដោយកងចក្រ ដូចដួង ព្រះអាទិត្យ ដូចដួងព្រះចន្ទ ដែលមនុស្សនិង ទេវតាគប្បីបូជាដោយគោរព ។*

[១៩] មគ្គោទក្បម្បៀន មុហាបដិយាសាទិឧល្លោលវីចឹ
សំសារោឃំ តរិ តមភយំ ចារបត្តំ បជានំ
តាណំ លេណំ អសមសរណំ ឯកតិត្ថំ បតិដ្ឋំ
បុញ្ញក្ខេត្តំ បរមសុខទំ ធម្មរាជំ នមាមិ។

*ព្រះធម្មរាជាអង្គឯណា ទ្រង់ឆ្លងអន្លង់ទឹក គឺ*

សង្សារវដ្ត ដែលមានរលកតូចធំ គឺទោសៈ
មោហៈ និងតណ្ហា ដោយផែ គឺអរិយមគ្គ
ខ្ញុំសូមនមស្ការព្រះធម្មរាជាអង្គនោះ ដែល
មិនមានភ័យ ទ្រង់យាងដល់ច្រាំងហើយ
ទ្រង់ជាអ្នកគ្រប់គ្រងរក្សាពួកប្រជា ទ្រង់
ជាទីពួនចាកភ័យ ទ្រង់ជាទីពឹងមិនមាន
អ្នកណាដូច ទ្រង់ជាកំពង់នាំទៅព្រះនិព្វាន
ទ្រង់ជាទីពួកសត្វតាំងនៅ ទ្រង់ជាបុញ្ញក្ខេត្ត
ទ្រង់ប្រទានបរមសុខ ។

[២០] កណ្ឌម្ពមូលេ បរហិតករោ យោ មុនិន្ទោ និសិន្នោ
អច្ចេរំ សីឃំ នយនសុភគំ អាកុលណ្ហគ្គិជាលំ
ទុដ្ឋាលទ្ធំសំ មុនិភិជហិតំ ចាដិហេរំ អកាសិ
វន្ទេ តំ សេដ្ឋំ បរមរតិជំ ឥទ្ធិធម្មេហុបេតំ។

ព្រះមុនិន្ទអង្គណា ទ្រង់បំពេញប្រយោជន៍ដល់អ្នក
ដទៃ គង់ក្នុងបរិវេណដើមកណ្ឌម្ពព្រឹក្ស បានធ្វើ
បាដិហារ្យ ដែលព្រះមុនីទាំងឡាយមិនទ្រង់លះបង់
មានភ្លើងនិងក្រសែទឹកលាយគ្នា គួរអស្ចារ្យ រហ័ស
គួរគយគន់ កម្ចាត់សំណាញ់នៃទិដ្ឋិ ខ្ញុំសូមនមស្ការ

*ព្រះមុនីជាម្ចាស់អង្គនោះ ដែលជាបុគ្គលដ៏ប្រសើរ ញុំាងសេចក្ដីត្រេកអរឲ្យកើតយ៉ាងក្រៃលែង មានឥទ្ធិគុណ ។*

[២១] មុនិន្ទក្កោ យ្វេកោ ឧយុឧយរុណោ ញាណាវិត្ថិណ្ណាពិម្ពោ
វិនេយ្យប្បាណោឃំ កមលកជិតំ ធម្មរំសីវរេហិ
សុពោធេសិ សុទ្ធេ តិភវកុហរេ ព្យាបិតក្កិត្តិធញ្ញុ
តិលោកេកច្ចក្ខុំ ធុខមសហាធំ តំ មហេសិំ នមាមិ។

*ព្រះអាទិត្យ គឺព្រះមុនិន្ទ មួយដួង មានពន្លឺអរុណ គឺមហាករុណាឧទ័យឡើងមក មានបរិមណ្ឌល គឺសព្វញ្ញុតញ្ញាណដ៏ធំទូលាយ ញុំាងផ្កាកមលៈ គឺពួកវេនេយ្យសត្វ ក្នុងស្រះ គឺភពទាំង ៣ ដ៏ថ្លាស្អាត ឲ្យត្រជាក់រីករាយ គឺត្រាស់ដឹង ដោយរស្មី គឺព្រះសទ្ធម្មដ៏ប្រសើរ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យ គឺព្រះមុនិន្ទអង្គនោះ ដែលមានកិត្តិស័ព្ទផ្សាយទៅហើយ ជាដួងភ្នែកមួយដួងក្នុងលោកទាំង ៣ ដែលអត់សង្កត់នូវវត្ថុដែលលំបាក ជាអ្នកស្វែងរកបុណ្យ ។*

[២២] យោ ជិនោ អនេកជាតិយំ សបុត្តទារមង្គជីវិតម្បិ
ពោធិបេមតោ អលគ្គមានសោ អទាសិយេវ អត្ថិកស្ស

ទានបារមី តតោ បរំ អប្បរិ សីលបារមាទិកម្បិ

តាសមិទ្ធិយោបយាតមគ្គតំ តមេកទីបកំ នមាមិ។

*ព្រះជិនស្រីជាម្ចាស់អង្គឯណា ទ្រង់មានព្រះហឫទ័យ មិនជាប់ជំពាក់ ព្រោះសេចក្តីស្រឡាញ់ក្នុងពោធិញ្ញាណ ទើបបានលះនូវកិរិយា ព្រមទាំងបុត្រ អវយវៈនិង ជីវិត ឲ្យដល់អ្នកត្រូវការច្រើនកពជាតិហើយ ក្រៅពី នោះនៅបំពេញទានបារមី សីលបារមីជាដើម ខ្ញុំសូម នមស្ការនូវព្រះជិនស្រីជាម្ចាស់អង្គនោះ ជាដួងប្រទីប មួយដួង ជាអ្នកដល់ភាពដ៏ប្រសើរ ព្រោះផលនៃ បារមីនោះ ฯ*

[២៣] ទេវាទេវាតិទេវំ និធនវបុធរំ មារភង្គំ អភង្គំ

ទីបំ ទីបំ បជានំ ជយវរសយនេ ពោធិបត្តំធិបត្តំ

ព្រហ្មាព្រហ្មាគតានំ វរគិរកថិកំ បាបហីនំ បហីនំ

លោកាលោកាភិរាមំ សតតមភិនមេ តំ មុនិន្ទំ មុនិន្ទំ។

*ខ្ញុំសូមនមស្ការនូវព្រះមុនិន្ទជាម្ចាស់ ជាទេពកំពូលលើទេព និងមិនមែនទេព ទ្រទ្រង់ទុកនូវអត្តភាពចុងបំផុត កម្ចាត់នូវ មារ ដែលគ្មានអ្នកណាកម្ចាត់បាន ទ្រង់ទ្រោលប្រទីបឲ្យពពួក សត្វ ទ្រង់សម្រេចនូវពោធិញ្ញាណលើពោធិបល្លង្ក ដែលជា*

ស្ថានទីឈ្នះមារ និងជាស្ថានទីគួរគ្រេកអរ ទ្រង់សម្ដែងធម៌
ដ៏ប្រសើរដល់ព្រហ្ម ទេវតា និងមនុស្សរួចមករក ទ្រង់លះ
បាបបានហើយ ទ្រង់កាត់អកុសលដាច់ហើយ ជាទីត្រេកអរ
របស់មនុស្សលោកនិងទេវលោក ដែលជាព្រះមុនិន្ទ ។

[២៨] ពុទ្ធោ និគ្រោធពិម្ពោ មុទុករចរណោ ព្រហ្មឃោសេណិជង្ឃោ
កោសច្ឆាទង្គជាតោ បុនរបិ សុគតោ សុប្បតិដ្ឋិតបាទោ
មូលោទាតុណ្ណលោមោ អថមបិ សុគតោ ព្រហ្មុជុគ្គត្តភាវោ
នីលក្ខី ទីឃបណ្ហី សុខុមមលឆវី ថោម្យរសគ្គសគ្គី។

ព្រះពុទ្ធជាម្ចាស់ មានព្រះវរកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ
មានផ្ទៃព្រះហស្ដនិងផ្ទៃព្រះបាទដ៏ទន់ល្មើយ មានព្រះជង្ឃា គឺស្មង
វៀវមូលត្រសូល ដូចជង្ឃានៃព្រហ្ម មានព្រះអង្គាវយវៈ ដែលត្រូវ
លាក់កំបាំងដោយសំពត់ស្ថិតនៅក្នុងស្រោម ទ្រង់យាងទៅល្អ
មានផ្ទៃព្រះបាទទាំងគូរាបស្មើល្អ មានព្រះលោមាដ៏ទន់ពណ៌មាស
មានព្រះសួរស័ព្ទដ៏ពីរោះ មានព្រះកាយត្រង់ដូចជាកាយនៃព្រហ្ម
មានព្រះនេត្រខៀវស្រស់ មានកែងព្រះបាទវែង មានព្រះឆវី
ល្អិតផូរផង់រលីងស្រិល មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារ
ដ៏លើសលែង សម្រាប់ទទួលរសអាហារ ។

[២៩] ចត្តាលីសគ្គទន្តោ សមកលបទជោ អន្តរំសប្បពីនោ

ចក្កង្កិតចរណោ អវិរឡ្ហទសនោ មារជុស្សង្ខចរណោ

តិដ្ឋន្តោ នោនមន្តោភយការមុទុនា ជណ្ណុកានាមសន្តោ

វដ្ដក្ខន្ធោ ជិនោ គោតរុណបខុមកោ សីហបុព្វឌ្ឍកាយោ។

*មានព្រះទន្ត ៤០ គត់ មានព្រះទន្តស្មើគ្នា មានព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ មានផ្ទៃព្រះបាទប្រដាប់ដោយចក្រ មានព្រះទន្តជិតស្និទ្ធល្អ ទ្រង់ឈ្នះមារ មានព្រះបាទដូចជាអណ្ដែតឡើងខាងលើដូចជាស័ង្ខ កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះ អាចស្ទាបអង្អែលព្រះជានុបាន មានព្រះស្បូវងមូលសម មានដួងព្រះនេត្រដូចជាភ្នែកនៃកូនគោ មានព្រះកាយពាក់កណ្ដាលខាងលើ ដូចជាកាយនៃរាជសីហ៍។*

[២៦] សត្តុស្សទោ ច ទីឃង្គុលិ មថ សុគតោ លោមកូបេកលោមោ

សម្បន្នោទាតទាឋោ កនកសមតចោ នីលមុទ្វគ្គលោមោ

សម្តុទ្ធោ ចូលជិវ្ហោ អថ សីហហនុកោ ជាលិកប្បាទហត្ថោ

នាថោ ឧណ្ហីសសីសោ ឥតិគុណសហិតំ តំ មហេសឹ នមាមិ។

*ព្រះសុគតជាម្ចាស់ មានព្រះមំសៈគឺសាច់ ៧ អន្លើដោយបរិបូណ៌ (គឺខ្នងព្រះហស្ត ២, ខ្នងព្រះបាទ ២, ព្រះអង្សា ២, ព្រះស្ករង ១) មានព្រះអង្គុលិវែងស្មើគ្នា មានព្រះលោមាតែ ១ សរសៃ ៗ គឺក្នុងរណ្ដៅរោម ១ មានរោម ១ មានព្រះទាឋា គឺចង្កូមកែវទាំង ៤*

សស្អាត មានស្បែកសម្បុរថ្លៃ (លឿងភ្លឺអន្ទង់) ដូចជាសម្បុរនៃ
មាស មានព្រះលោមាពណ៌ខៀវមានចុង-ងឡើងលើ ព្រះសម្ពុទ្ធ
មានព្រះជិវ្ហាដ៏ធំវែងទន់ មានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍
ផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទ មានប្រទាក់ក្រឡាដូចជាសំណាញ់
ព្រះលោកនាថ ទ្រង់មាននលាដ៍និងព្រះសីរប្បរិបូណ៌ ខ្ញុំសូម
នមស្ការនូវព្រះសុគត ដែលសម្បូរណ៍ដោយព្រះគុណ ដូច
ពោលមកនេះ ទ្រង់ស្វែងរកនូវព្រះគុណដ៏ធំក្រៃលែង ។

[២៧] ពុទ្ធោពុទ្ធោតិឃោសោ អតិទុលភតរោ កោ កថា ពុទ្ធភាវោ
លោកេ តស្មា វិភាវី វិវិធហិតសុខំ សាធវោ បត្ថយន្តា
ឥដ្ឋំ អត្ថំ វហន្តំ សុរនរមហិតំ និព្ភយំ ទក្ខិណេយ្យំ
លោកានំ នន្ទិវឌ្ឍំ ទសពលមសមំ តំ នមស្សន្តុ និច្ចំ។

សំឡេងប្រកាសថា ពុទ្ធោ ពុទ្ធោ ឮបានដោយកម្រក្រៃពេក នឹង
បាច់ពោលទៅថ្វី ភាពជាព្រះពុទ្ធ ដូច្នោះ សាធុជនអ្នកមានបញ្ញា
ប្រាថ្នាប្រយោជន៍សុខ មានប្រការផ្សេងៗក្នុងលោក ចូរនមស្ការ
នូវព្រះពុទ្ធជាម្ចាស់ ដែលគួរចូលគាល់ ទ្រង់ទ្រទ្រង់ទុកនូវ
ប្រយោជន៍ ដែលទេវតានិងមនុស្សនាំគ្នាបូជា ទ្រង់មិនមាន
ភ័យ ជាទក្ខិណេយ្យ អ្នកញ៉ាំងសេចក្តីត្រេកអរឲ្យចម្រើន
ដល់សត្វលោក អ្នកមានកម្លាំង ១០ គ្មានបុគ្គលណាស្មើ
ដូចព្រះអង្គ អស់កាលជានិច្ច ។

[២៨]បុញ្ញេនេតេន សោហំ និបុណមតិ សតោ សម្បរាយេ ច តិត្តោ
ទក្ខោ ទិដ្ឋុដ្ឋុបញ្ញោ អវិកលវីរិយោ ភោគវា សំវិភាគី
តិក្ខោ សូរោ ថិតត្តោ សបរហិតចរោ ទីឃជីវី អរោគោ
ធញ្ញោ វណ្ណោ យសស្សី អតិពលវធរោ កិត្តិមា ខន្តុបេតោ។

*ដោយបុណ្យដែលកើតពីការនមស្ការនោះ សូមឲ្យខ្ញុំជាអ្នកមានបញ្ញាសុខុម មានសតិ រីករាយក្នុងសម្បរាយភព ជាមនុស្សឈ្លាស ជាមនុស្សត្រង់ មានសម្មាទិដ្ឋិ មានសេចក្តីព្យាយាមមិនរួញរា ជាមនុស្សមានភោគសម្បត្តិ ជាមនុស្សចែករំលែក ជាមនុស្សមានបញ្ញាចាស់ក្លា ជាមនុស្សក្លាហាន ជាមនុស្សមានចិត្តរឹងមាំ ប្រព្រឹត្តប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ មានអាយុវែង មិនមានរោគ មានបុណ្យ មានសម្បុរល្អ មានយស មានកម្លាំងពលំ មានកិត្តិស័ព្ទ មានសេចក្តីអត់ធន់ ។*

[២៩]សទ្ធោ ទាតត្ថុបេតោ បរមសិរិធរោ ទិដ្ឋធម្មេ វិរត្តោ
លទ្ធី កល្យាណមិត្តោ អភិរតកុសលោ បញ្ចសីលាភិរក្ខោ
អប្បិច្ឆោ អប្បកោធោ អតិរុជុហាទយោ ឥទ្ធិមា អប្បមេយ្យោ
ចាសំសោ បេមវាចោ សុជនគុណវិទូ មាមកោ សោ ភវេយ្យំ។

*ជាមនុស្សមានសទ្ធា សម្បូរណ៍ដោយទ្រព្យសម្បត្តិ សម្រាប់ឲ្យ*

ជាទាន មានសិរីវដ្ឍន៍ខ្ពស់ ត្រេកអរក្នុងទិដ្ឋធម៌ ជាមនុស្សលជ្ជី មានកល្យាណមិត្ត ត្រេកអរក្រៃលែងក្នុងកុសលធម៌ អាចរក្សាសីល ៥ បាន ជាមនុស្សប្រាជ្ញាតិច មានសេចក្ដីក្រោធតិច មានចិត្តទៀងត្រង់ក្រៃលែង មានឫទ្ធិ មានគុណរកប្រមាណមិនបាន ជាអ្នកគួរសរសើរ ពោលបិយវាចា ដឹងគុណរបស់មនុស្សល្អ ជាអ្នកគោរពរាប់កាន់ព្រះពុទ្ធសាសនា ។

[៣០] ឥត្ថំ អសង្ខ្យេ នាថ– គុណោ លក្ខណាទីបិតេ
គាថាសុ សូចកាស្វេក– គាថម្បិ សរតេ ពុធោ។

បណ្ឌិតណា កាលបានឮគេប្រកាសគុណលក្ខណៈរបស់ព្រះលោកនាថ ដែលប្រមាណមិនបាន ដោយប្រការដូច្នេះហើយ ទ្រទ្រង់ចាំគាថា ១ គាថា ក្នុងបណ្ដាគាថាទាំងឡាយបាន ។

[៣១] ចតុរាបាយមុត្តោ សោ សាធកត្ថទ្វយស្ស ច
ហតូបទ្ទវជាលោ ច លាភី ហិតសុខស្ស ច។

បណ្ឌិតនោះ នឹងរួចផុតចាកអបាយភូមិទាំង ៤ នឹងជាអ្នកញុំាងប្រយោជន៍ទាំងពីរឲ្យសម្រេច នឹងជាអ្នកកម្ចាត់សំណាញ់ គឺឧបទ្រពបាន នឹងបានទទួលប្រយោជន៍ជាសុខ ។

[៣២] អធិបោ នរនារីនំ ចតុទ្ទីបិស្សរោបិ វា

ភវេយ្យ អត្ថិមេ ទេហេ តមញ្ញំ សេតឆត្តកំ។

[៣៣] ភាវនាយានមារុយ្ហ សមមេស្សតិ សុព្វតោ

ឥមស្មិំ អត្តភាវេបិ អរោគោ ទីឃជីវិកោ។

*នឹងជាធំក្នុងទេវតានិងមនុស្ស នឹងកើតជាស្តេចចក្រពត្តិ ជាធំក្នុងទ្វីបទាំង ៤ ក្នុងអត្តភាពចុងបំផុត នឹងជាអ្នកមានសេចក្តីប្រព្រឹត្តល្អ ឡើងកាន់យាន គឺភាវនា ដែលទ្រទ្រង់ទុកនូវស្វេតច្ឆត្រ គឺអរហត្តផលនោះ ទៅដល់ព្រះនិព្វាន សូម្បីក្នុងអត្តភាពនេះ ក៏នឹងជាមនុស្សមានអាយុវែង មិនមានរោគ ។*

[៣៤] បូជិតោ សព្វលោកេហិ ភាវនាភិរតមនោ

ជនប្បិយោ មនាបោ ច កា កថាវិលធារណោ។

*ជាអ្នកមានចិត្តត្រេកអរក្នុងភាវនា ជាអ្នកដែលមនុស្សលោកទាំងពួង គោរពបូជាហើយ ជាទីស្រឡាញ់ ជាទីពេញចិត្តនៃមហាជន នឹងចាំបាច់ពោលទៅថ្វី ក្នុងការការទ្រទ្រង់ចាំគាថាបានទាំងអស់ ។*

**ចប់នមក្ការបាលី-ប្រែ ត្រឹមតែប៉ុណ្ណេះ ។**

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្មារដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទៈ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែលៈ maha.panna@gmail.com

គេហទំព័រៈ http://www.mahapanna.org

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~